Japan, your neighbor

ញ្ញឹមខ្មែរ
NyoNyum Khmer

៥៥
ឥតគិតថ្លៃ!
មករា-កុម្ភៈ ២០២៣

ស្ថានភាពតាំទ្រការផ្សាយសោតទស្សន៍នៅកម្ពុជា

© CJSinc. 2023

មាតិកា ៥៥

មកា - កម្ម ២០២៣

• អត្ថបទពិសេស

០៣ **ស្ថានភាពគាំទ្រការផ្សាយសោតទស្សន៍នៅកម្ពុជា**

០៤ **បណ្តាញក្រុមហ៊ុនទូរទស្សន៍ធំៗទាំង ៣ និងទូរទស្សន៍ពេញនិយមដទៃនៅកម្ពុជា**
ក្រុមហ៊ុន CBS
ទូរទស្សន៍ CTN

០៥ ទូរទស្សន៍ MYTV
ទូរទស្សន៍ CNC

០៦ **ក្រុមហ៊ុនទូរទស្សន៍ ឬាយ័ន**
"តោះនិយាយ! ហាមកុហក!"
"សំណើចចុងសប្តាហ៍"

០៧ V TALK Confession

០៧ **ទូរទស្សន៍** BTV

០៨ **ក្រុមហ៊ុន បាង្សមាស**
កម្មវិធី Cambodian Idol

០៩ ចំណាប់អារម្មណ៍អ្នកនិយមចូលចិត្តកម្មវិធី Cambodian Idol

១០ កម្មវិធី The Voice Kids Cambodia

១១ **ក្រុមហ៊ុនទូរទស្សន៍ពេញនិយមដទៃ**
ទូរទស្សន៍ PNN
ទូរទស្សន៍ TV5
ទូរទស្សន៍ជាតិកម្ពុជា TVK

១២ **តើអ្នកចូលចិត្តទស្សនាទូរទស្សន៍តាមកញ្ចក់ទូរទស្សន៍ ឬតាមទូរសព្ទស្មាតហ្វូន?**

១៤ **ទិន្នន័យអង្កេតការអំពីស្ថានភាពទស្សនាកម្មវិធីសោតទស្សន៍**

១៥ **ត្រួសៗអំពីដើមកំណើតផ្សាយទូរទស្សន៍ សន្ទុះអ្នកទស្សនាកម្មវិធីផ្សាយតាមបណ្តាញសង្គម និងស្មាតហ្វូន**

• ប្រធានបទប្រចាំ

១៦ **គយគន់ទេសភាពប្រទេសជប៉ុន** Japan View
ដំណើរកម្សាន្តវិលល្ងាចពីទីក្រុងតូក្យូ រមណីយដ្ឋានព្រិលទឹកកក Fujiten Snow Resort & ឆូមិបុរាណា Oshinohakkai

១៨ **សេចក្តីរាយការណ៍ពីប្រទេសជប៉ុន** Report from Japan
"ជនជាតិជប៉ុនមានវប្បធម៌ការងារល្អៗជាច្រើនដែលខ្មែរយើងគួរស្វែងយល់ និងរៀនសូត្រ"

២០ **ហោរាសាស្ត្រប្រចាំខែ** Fortune Telling
ហោរាសាស្ត្រប្រចាំខែមករា និងកុម្ភៈ

២២ **ស្វែងយល់អំពីប្រទេសជប៉ុន**
About JAPAN
ព័ត៌មានមូលដ្ឋានអំពីប្រទេសជប៉ុន / អាកាសធាតុនិងរដូវ / ផែនទីជប៉ុន

កំណត់ត្រាអ្នកនិពន្ធ

បុគ្គលិកទស្សនាវដ្តីញញឹមខ្មែរយើងខ្ញុំ សូមអបអរសាទរឆ្នាំថ្មីឆ្នាំសកល២០២៣ និងសូមប្រសិទ្ធិពរជ័យជូនប្រិយមិត្តអ្នកអានឱ្យទទួលបានសេចក្តីសុខ សុភមង្គល និងជោគជ័យរាល់គ្រប់ភារកិច្ចសម្រាប់ឆ្នាំថ្មីនេះ។

សម្រាប់ការចុះផ្សាយអត្ថបទពិសេសក្នុងលេខ៥៥នេះ ក្រុមការងារយើងខ្ញុំបានសម្រេចចិត្តស្រាវជ្រាវអំពីស្ថានភាពនៃការទស្សនាកម្មវិធីទូរទស្សន៍នាពេលបច្ចុប្បន្ននៅកម្ពុជាយកមកចុះផ្សាយជូនប្រិយមិត្តអានកម្សាន្ត និងស្វែងយល់ពីប្រធានបទនេះ។ ជាការពិតណាស់ សន្ទុះអ្នកប្រើប្រាស់បណ្តាញសង្គមបានកើនឡើងច្រើនសន្ធឹកសន្ធាប់នាពេលបច្ចុប្បន្ន បានធ្វើឱ្យចំនួនអ្នកទស្សនាកម្មវិធីទូរទស្សន៍តាមទូរសព្ទដៃស្មាតហ្វូនកើនឡើងជាលំដាប់។ ស្ថិតនៅក្នុងស្ថានភាពបែបនេះ តើក្រុមហ៊ុនទូរទស្សន៍ត្រូវខិតខំប្រឹងប្រែងដូចម្តេចខ្លះ ដើម្បីទាក់ទាញអ្នកទស្សនា? ម្យ៉ាងទៀត តើប្រជាពលរដ្ឋទូទៅគិតយ៉ាងណាចំពោះការទស្សនាកម្មវិធីសោតទស្សន៍ ដែលកំពុងវិវត្តន៍ខ្លួននាពេលបច្ចុប្បន្ន?

តាមរយៈការចុះផ្សាយលើកនេះ យើងខ្ញុំរំពឹងថាវានឹងផ្តល់នូវព័ត៌មានគោលៗមួយចំនួនជូនប្រិយមិត្តអ្នកអានសម្រាប់យកទៅសង្កេត និងពិចារណាលើទំនោរនៃការតាមដានទស្សនាកម្មវិធីសោតទស្សន៍នៅកម្ពុជានាពេលបច្ចុប្បន្ន និងអនាគតខាងមុខ។

តំណាងក្រុមអ្នកនិពន្ធ
nyonyum@cisinc.co.jp

ញញឹមខ្មែរ
NyoNyum Khmer
nyonyum.net

© CJSinc. 2023
រក្សាសិទ្ធិគ្រប់បែបយ៉ាងរាល់ការចតចម្លងដោយគ្មានការអនុញ្ញាត នឹងត្រូវផ្តន្ទាទោសតាមច្បាប់

គ្រប់គ្រងការបោះពុម្ពផ្សាយ
យ៉ាម៉ាហ្សាគី យូគីអេ

ក្រុមនិពន្ធ និងទីផ្សារ
កាណូ ហ៊ីរ៉ូអាគី
អូន ចិន្តា
តានីហ្គាកិ ម៉ូអ៊ិ
ណុប វិសាល
សារឿន ភារិទ្ធ
ឈឺន ឈន់
សុន រស្មី

ផ្នែកអ្យាបចំ និង រចនា
អ៊ូន ចាន់រ៉ា

ស្ថានភាពគាំទ្រការផ្សាយសោតទស្សន៍នៅកម្ពុជា

វិស័យសោតទស្សន៍នៅកម្ពុជាមានការប្រកួតប្រជែងខ្លាំងគួរឱ្យកត់សម្គាល់ នៅឆ្នាំ២០១២។ នាដើមខែមករា ឆ្នាំ២០១២ ក្រុមហ៊ុន ហង្សមាស ដែលបច្ចុប្បន្នជាក្រុមហ៊ុនទូរទស្សន៍ឯកជនដ៏ល្បីល្បាញបំផុតមួយនៅកម្ពុជា បានចាប់ផ្តើមផ្សាយសាកល្បងកម្មវិធីទូរទស្សន៍របស់ខ្លួនដំបូងដើម្បីចូលរួមប្រកួតប្រជែងជាមួយក្រុមហ៊ុនទូរទស្សន៍ដទៃទៀតដែលកំពុងមានសកម្មភាពនៅកម្ពុជា។

អំឡុងឆ្នាំ២០១៣ ដោយសារកំណើនអ្នកប្រើប្រាស់បណ្តាញសង្គម (ហ្វេសប៊ុកជាពិសេស) កើនឡើងខ្លាំងយ៉ាងគំហុក បានធ្វើឱ្យក្រុមហ៊ុនទូរទស្សន៍ងាកមកពង្រីកការផ្សាយតាមបណ្តាញសង្គមជាហូរហែ ដើម្បីទាក់ទាញអ្នកទស្សនាប្រើទូរសព្ទស្មាតហ្វូន ដែលកំពុងមានចំនួនច្រើនលើសលប់។

បច្ចុប្បន្ន តើស្ថានភាពទស្សនាកម្មវិធីទូរទស្សន៍មានការប្រែប្រួល និងទទួលការចាប់អារម្មណ៍ពីទស្សនិកជនបែបណាខ្លះ?

បណ្តាញក្រុមហ៊ុនទូរទស្សន៍ធំៗទាំង ៣ និងទូរទស្សន៍ពេញនិយមដទៃនៅកម្ពុជា

CBS P.4-5
Bayon TV P.6-7
Hang Meas P.8-10
ប៉ុស្តិ៍ផ្សេងទៀត P.11

នៅខែមីនា ឆ្នាំ២០២២ តំណាងក្រុមហ៊ុនសម្ព័ន្ធទូរទស្សន៍កម្ពុជា (ដែលក្នុងនោះមានក្រុមហ៊ុនទូរទស្សន៍ធំៗ ចំនួន ៣ គឺក្រុមហ៊ុន CBS, ក្រុមហ៊ុន Bayon TV និងក្រុមហ៊ុន Hang Meas) បានព្រមព្រាងបង្កើតក្រុមហ៊ុនថ្នាលទូរទស្សន៍ឌីជីថលកម្ពុជា ឯ.ក ក្នុងគោលបំណងជម្រុញការផ្សព្វផ្សាយជាប្រព័ន្ធឌីជីថលមានគុណភាពខ្ពស់ក្នុងការបញ្ជូនរូបភាព និងសំឡេងទៅកាន់ទស្សនិកជននៅទូទាំងប្រទេសកម្ពុជា។ ក្រុមហ៊ុនចំនួន ៣ ខាងលើជាក្រុមហ៊ុនទូរទស្សន៍ចម្បងនៅកម្ពុជា។ តើបណ្តាញក្រុមហ៊ុនទាំង ៣ នេះ និងប៉ុស្តិ៍ទូរទស្សន៍ដទៃទៀត ដែលមានសមត្ថភាពផ្សាយគ្របដណ្តប់ធំទូលាយមានកម្មវិធីផ្សាយ និងការនិយមដូចម្តេចខ្លះ?

អត្ថន័យសញ្ញាប្រើក្នុងអត្ថបទនេះ

TV ម៉ោងផ្សាយ | ផ្សាយតាមបណ្តាញសង្គម | ចំនួនអ្នកតាមដានលើ FACEBOOK

CBS ក្រុមហ៊ុន CBS

ក្រុមហ៊ុន CBS បង្កើតឡើងដោយក្រុមហ៊ុនរ៉ូយ៉ាល់គ្រុប និងបានបង្កើតបណ្តាញទូរទស្សន៍កម្ពុជា (CTN) ក្នុងឆ្នាំ២០០៣ ។ ជាមួយនឹងពាក្យស្លោក “បង្កើនជីវភាពរស់នៅ របស់ប្រជាពលរដ្ឋកម្ពុជាទាំងអស់ តាមរយៈការផ្តល់ជូននូវកម្មវិធីទូរទស្សន៍លំដាប់កំពូល ដែលមានចំណេះដឹង ការអប់រំ និងបំផុសគំនិត” ក្រុមហ៊ុន CBS បានបន្តពង្រីកវិសាលភាពផ្សព្វផ្សាយរបស់ខ្លួន ដោយបង្កើតឡើងនូវកម្មវិធីទូរទស្សន៍ MYTV នាដើមឆ្នាំ២០០៩ និង CNC នៅពាក់កណ្តាលឆ្នាំ២០១២ ដើម្បីសម្របតាមតម្រូវការរបស់អ្នកទស្សនាកម្មវិធីទូរទស្សន៍នៅកម្ពុជា ដែលមានចំនួនច្រើនលើសលប់ជាងបណ្តាញផ្សព្វផ្សាយដទៃ។

CTN ទូរទស្សន៍ CTN

4.2 M Followers

ទូរទស្សន៍ CTN បង្កើតឡើងដំបូងដោយការបណ្តាក់ទុនរួមគ្នារវាងក្រុមហ៊ុន Royal Group និង Modern Times Group (ក្រុមហ៊ុនកម្សាន្តផ្នែកឌីជីថលប្រចាំសហភាពអឺរ៉ុប)។ នៅឆ្នាំ២០១៣ CTN បានក្លាយជាប៉ុស្តិ៍ទូរទស្សន៍មានប្រជាប្រិយភាពជាងគេនៅកម្ពុជា ដោយមានចំនួនអ្នកទស្សនាច្រើនជាឃ្យុវ័យ។

▲ ទិដ្ឋភាពសម្តែងនិងទស្សនាកម្មវិធីសំណើចតាមភូមិ

“សំណើចតាមភូមិ”

TV រាល់ថ្ងៃសៅរ៍ ពីម៉ោង ៩យប់ (ទស្សនាការសម្តែងផ្ទាល់តាមបណ្តាខេត្ត ចាប់ពីម៉ោង ៥ល្ងាច!)

កម្មវិធីប្រគុំតន្ត្រីទទួលបានការនិយមគាំទ្រច្រើនពីប្រជាពលរដ្ឋខ្មែរទូទៅ មិនថាចាស់ ឬក្មេងតាំងពីដើម រហូតមកដល់បច្ចុប្បន្ន។ ជាទូទៅកម្មវិធីប្រគុំតន្ត្រីចាក់ផ្សាយនៅអំឡុងម៉ោងសម្រាកពីការងារពិសេសម៉ោងក្រោយអាហារពេលល្ងាច និងថ្ងៃចុងសប្តាហ៍។ កម្មវិធីប្រគុំតន្ត្រីភាគច្រើនទទួលបានការឧបត្ថម្ភធំ ដោយក្រុមហ៊ុនភេសជ្ជៈ ផ្សាយពេញមួយឆ្នាំ ឬតាមរដូវកាល។ “សំណើចតាមភូមិ” ជាកម្មវិធីប្រគុំតន្ត្រីរបស់ទូរទស្សន៍ CTN ធ្វើឡើងនៅតាមស្រុកស្រែពេញនិយមតាំងពីដើមរហូតដល់បច្ចុប្បន្ន។

លក្ខណៈពិសេសនៃកម្មវិធី៖

- មានបង្ហាញជារឿងរ៉ាវខ្លីៗពីទិដ្ឋភាពពិសេសៗនៅភូមិស្រុក ឬខេត្តដែលព្រឹត្តិការប្រគុំតន្ត្រីចុះទៅផ្ទាល់ (ឧ. ការណែនាំពីតំបន់រមណីយដ្ឋានសំខាន់ៗ ឬអាហារពិសេសប្រចាំតំបន់ និងការលេងល្បែងកម្សាន្តនានាជាដើម)
- មានតារាកំប្លែងផ្លាស់ប្តូរគ្នាពីមួយជំនាន់ទៅមួយជំនាន់ដូចជា៖ ក្រុម នាយកុយ និងនាយក្រឹម > ពាក់មី > ក្រុមកំប្លែងពូណុយ និងពូណម

MyTV ទូរទស្សន៍ MYTV

4.1 M Followers

MYTV បើកដំណើរការផ្សាយនៅដើមឆ្នាំ២០០៨ ជាផ្នែកផ្សព្វផ្សាយថ្មីមួយបន្ទាប់ពីទូរទស្សន៍ CTN និងមានប្រជាប្រិយភាពចំពោះយុវជន។ MYTV ផ្តោតសំខាន់លើការបង្កើតកម្មវិធីកម្សាន្តដោយខ្លួនឯង ជាពិសេស ដើម្បីចូលរួមលើកកម្ពស់ការច្នៃប្រឌិតកម្មវិធីសិល្បៈកម្សាន្តនៅកម្ពុជា។ ប៉ុស្តិ៍ MYTV នេះក៏ពេញនិយមចំពោះកម្មវិធីចាក់ផ្សាយរឿងភាគខ្មែរ និងបរទេសមានដូចជា៖ ឥណ្ឌា ហ្វីលីពីន និងចិន ជាដើមផងដែរ។

កម្មវិធី «កំពូលមិត្ត»

TV រាល់ថ្ងៃចន្ទ ពីម៉ោង៖ ៨ ដល់ ៩ យប់

ជាកម្មវិធីសំណើចដែលរៀបរៀងឡើងជាសាច់រឿងបែបកំប្លែងដោយនិយាយពិភាក្សាគ្នាពីរឿងនេះរឿងនោះរបស់តួអង្គ ៦នាក់ដែលជាមិត្តភក្តិនឹងគ្នា។

«នាងខ្ញុំទស្សនាកម្មវិធី “កំពូលមិត្ត” ម្តងម្កាលដើម្បីកម្សាន្តអារម្មណ៍។ នាងខ្ញុំសង្កេតឃើញថាកម្មវិធីនេះទទួលបានការគាំទ្រច្រើនពីសំណាក់យុវវ័យ ព្រោះវាក៏ជាកម្មវិធីមួយដែលអាចធ្វើឱ្យអ្នកទស្សនាផ្ទុះសំណើចបានដោយឈុតនិយាយកំប្លែងក្រមិចក្រមើមពីសំណាក់តួអង្គសម្តែង»។

កញ្ញា ឈាវ ចាំម (២៣ឆ្នាំ)
និស្សិតនៅវិទ្យាស្ថានភាសាបរទេស (IFL)

«នាងខ្ញុំធ្លាប់មើលកម្មវិធីនេះ តាមទូរទស្សន៍ CTN ពេលទំនេរពីការសិក្សា។ នាងខ្ញុំតែងតែមើលកម្មវិធីនេះ ព្រោះចូលចិត្តការបកស្រាយចម្រៀងសម័យដើម និងការសម្តែងកំប្លែងរបស់ក្រុមនាយពាក់មី។ លើសពីនេះ នាងខ្ញុំក៏ចូលចិត្តមើលពីទិដ្ឋភាពនៅស្រុកស្រែដែលកម្មវិធីសំណើចតាមភូមិឋតមកចាក់ផ្សាយផងដែរ»។

កញ្ញា ម៉ែង សាវិន (២៣ឆ្នាំ)
គ្រូបង្រៀន នៅរាជធានីភ្នំពេញ

កម្មវិធី «ពីនេះពីនោះជាមួយសុខគា»

TV រាល់ថ្ងៃចន្ទ ពីម៉ោង៖ ៩ ដល់ ១០យប់

Facebook

◀ ឈុតអ្នកទស្សនាសួរសំណួរទៅកាន់តារាកិត្តិយស

ជាកម្មវិធីពិភាក្សាសួរដេញដោលជាមួយសំនួនវ៉ាហារសព្វមិនចេះរីងសួតពីសំណាក់លោកសុខគា ទៅកាន់តារាកិត្តិយសជាសិល្បការខ្មែរ។

«ខ្ញុំទើបតែបានឃើញកម្មវិធីនេះកាលពី ២ខែមុនតាមហ្វេសប៊ុក។ តាំងពីនោះមក ខ្ញុំចូលចិត្តមើលកម្មវិធីនេះខ្លាំងណាស់ និងឧស្សាហ៍តាមដាននៅលើផេកហ្វេសប៊ុក MYTV។ ពេលមើលកម្មវិធីនេះ ធ្វើឱ្យខ្ញុំមានអារម្មណ៍សប្បាយ ទៅតាមពិធីការដែលតែងតែសួរសំណួរកំប្លែងៗ និងចាក់ដោតពីនេះពីនោះ ដើម្បីឱ្យតារាកិត្តិយសឆ្លើយ»។

លោក សារឿន តារិន (២១ឆ្នាំ)
កសិករ រស់នៅខេត្តកំពង់ចាម

អំពី

ទូរទស្សន៍ CNC

CNC បានសម្ពោធការផ្សាយនៅឆ្នាំ២០១២។ ជាបណ្តាញទូរទស្សន៍ពេញនិយមមួយរបស់ក្រុមហ៊ុន CBS បន្ទាប់ពីប៉ុស្តិ៍ CTN និង MYTV ។ CNC ផ្តោតការផ្សាយលើកម្មវិធីព័ត៌មានជាតិ និងអន្តរជាតិ រួមទាំងកម្មវិធីប្រកួតកីឡាប្រដាល់ជាតិ កីឡាបាល់ទាត់អន្តរជាតិ។

1.7 M Followers

Bayon TV ⋮ ក្រុមហ៊ុនទូរទស្សន៍ បាយ័ន

2.3 M Followers

ទូរទស្សន៍បាយ័ន ផ្តើមដំណើរការផ្សាយដំបូងនៅឆ្នាំ១៩៩៨ និងបានពង្រីកការផ្សព្វផ្សាយជាបន្តបន្ទាប់ តាមរយៈកម្មវិធីព័ត៌មានជាតិ អន្តរជាតិ កម្មវិធីអប់រំ ការប្រគុំតន្ត្រី និងកីឡាប្រដាល់គុនខ្មែរជាដើម។ ទូរទស្សន៍បាយ័ន និង BTV ជាសមាជិកគ្រួសារតែមួយផ្សាយក្នុងស្ថានីយ៍ទូរទស្សន៍បាយ័ន ដោយផ្តោតលើការបង្កើតកម្មវិធីកម្សាន្តមួយចំនួនថ្មីៗ និងទំនើបៗ ដើម្បីទាក់ទាញយុវវ័យខ្មែរដែលកំពុងមានចំនួនច្រើន។

“តោះនិយាយ! ហាមកុហក!” Let Chat Don’ t Cheat!

TV រាល់ថ្ងៃអាទិត្យ ម៉ោង៖ ៩ ដល់ ១០យប់

BAYON TV & 3Fun channel Cambodia FB page

▶ឈុតសួរដេញដោលភ្ញៀវកិត្តិយសពីសំណាក់ពិធីករទាំង៣រូប

បច្ចុប្បន្ន មានយុវវ័យជាច្រើននិយមទស្សនាកម្មវិធី talk show បែបកំប្លែងៗដើម្បីសើចសប្បាយ។ កម្មវិធីនេះ មានការចូលរួមសម្តែងដោយតារាកិត្តិយសល្បីៗ ដើម្បីឆ្លើយអំពីរឿងពិត។ លើសពីនេះ អ្នកទស្សនាអាចសើចសប្បាយជាមួយ ការលេងហ្គេម Challenging និង វគ្គ១០សំណួរ ដែលគេមិនធ្លាប់ដឹងពីតារាកិត្តិយស។

«ព្រោះវាជាកម្មវិធីកម្សាន្តបែបយុវវ័យដែលមានលាយឡំនឹងចំណេះដឹងទូទៅដែរ ទើបធ្វើឱ្យនាងខ្ញុំតាមដានមើលដើម្បីកម្សាន្តអារម្មណ៍។ នាងខ្ញុំភាគច្រើនមើលតែតារាកិត្តិយសរូបណាដែលស្គាល់ និងចូលចិត្តប៉ុណ្ណោះ។ ពិតណាស់ កម្មវិធីនេះបានជួយឱ្យអារម្មណ៍ខ្ញុំសប្បាយ ហើយ show ខ្លះក៏មានរឿងគួរឱ្យភ្ញាក់ផ្អើលដែរ ដ្បិតរឿងរ៉ាវជីវិតរបស់តារាកិត្តិយសមួយចំនួនស្តាប់ទៅពិតជាធ្វើឱ្យជក់ចិត្ត ហើយមានអារម្មណ៍ថាខ្សែជីវិតរបស់ពួកគាត់គួរឱ្យចាប់អារម្មណ៍ជាងខ្សែភាពយន្តទៅទៀត!»

កញ្ញា សាន សុភារ៉ា (២០ឆ្នាំ)
និស្សិតសិក្សានៅសាកលវិទ្យាល័យភូមិន្ទភ្នំពេញ

“សំណើចចុងសប្តាហ៍”

TV រាល់ថ្ងៃសៅរ៍ ម៉ោង ៥ ដល់ ៦ល្ងាច

ជាកម្មវិធីចាក់ផ្សាយខ្សែភាពយន្តភាគខ្មែរបែបកំប្លែង ដែលបង្កប់អត្ថន័យអប់រំ។ ដោយសារកម្មវិធីនេះចតផ្ទាល់នៅស្រុកភូមិកសិករខ្មែរ ដែលធ្វើឱ្យអ្នកទស្សនាក្នុងស្រុកជាពិសេសសម្រាប់ខ្មែរស់នៅក្រៅស្រុកបានសើចកម្សាន្តផង និងបានឃើញពីទិដ្ឋភាពស្រុកស្រែផ្ទាល់ផង ដែលធ្វើឱ្យគាត់នឹករលឹកពីប្រទេសកំណើតរបស់ខ្លួន។ លោក អ៊ូ ប៊ុនណ្ណារ៉ាត់ ហៅ នាយក្រឹម ដែលជាផលិតករ បានលើកឡើងពីលក្ខណៈពិសេសនៃកម្មវិធីនេះដូច្នេះថា៖ “មូលហេតុដែលខ្ញុំដឹកនាំក្រុមសម្តែងនៅតែក្នុងស្រុកភូមិជនបទ គឺក្នុងគោលបំណងចង់ឱ្យក្មេងជំនាន់ក្រោយ ក៏ដូចជាអ្នកនៅទីក្រុងដែលមិនសូវមានឱកាសបានធ្វើដំណើរទៅតាមបណ្តាខេត្តបានឃើញ និងយល់ដឹងពីរបៀបនៃការរស់នៅរបស់បងប្អូនប្រជាពលរដ្ឋដែលរស់នៅក្នុងស្រុកភូមិតូចៗតាមបណ្តាខេត្ត។ តែអ្វីកាន់តែពិសេសជាងនេះទៀត គឺសម្រាប់បងប្អូនខ្មែរនៅឯនាយសមុទ្រដែលមានចិត្តនឹករលឹកមាតុភូមិស្រុកកំណើតនៅពេលដែលបានទស្សនាក៏អាចជួយឱ្យរសាយចិត្តនឹករលឹកបានមួយគ្រា” ។

▲ឈុតមួយនៃកម្មវិធីសំណើចតាមភូមិ

«“សំណើចចុងសប្តាហ៍” ជាកម្មវិធីកម្សាន្តមួយដែលពេញនិយមសម្រាប់មនុស្សគ្រប់វ័យ។ វាជាកម្មវិធីកំប្លែងដែលធ្វើឱ្យអ្នកចូលរួមទស្សនារំសាយអារម្មណ៍ជាមួយការសម្តែងលាយឡំនឹងការក្លែមពាក្យពេចន៍របស់តួអង្គសម្តែង»។

លោក សឹម បុត្រធារិទ្ធ (២១ឆ្នាំ)
បុគ្គលិកក្រុមហ៊ុនរស់នៅក្នុងរាជធានីភ្នំពេញ

V TALK Confession

TV រាល់ថ្ងៃពុធ ពីម៉ោង ៩ ដល់ ១០យប់

បង្កើតឡើងនៅដើមខែកុម្ភៈ ឆ្នាំ២០២២។ កម្មវិធីនេះធ្វើការអញ្ជើញតារាកិត្តិយសជាសិល្បករសិល្បការនី ចូលរួមចែករំលែកនូវរឿងរ៉ាវបទពិសោធន៍ជីវិតជាច្រើននៅពីក្រោយភាពជោគជ័យ និងខ្សែជីវិតរបស់ពួកគាត់។ កម្មវិធីក៏អនុញ្ញាតឱ្យអ្នកទស្សនាចូលរួមជាមួយនឹងកម្មវិធី តាមរយៈការសរសេររឿងរ៉ាវរបស់ខ្លួនផ្ញើទៅកាន់កម្មវិធី ដើម្បីផ្តល់ឱកាសឱ្យសាម៉ីខ្លួនបកស្រាយអំពីទុក្ខកង្វល់របស់ខ្លួនទៅកាន់សាធារណជនផងដែរ។

«ក្រៅពីការទស្សនាកម្សាន្ត កម្មវិធីនេះអាចជួយរំសាយទុក្ខកង្វល់យើងបានមួយផ្នែកដែរ ដ្បិតក្នុងវគ្គខ្លះគឺយើងអាចទទួលចំណេះដឹង និងបទពិសោធន៍ជីវិត ដែលលើកឡើងដោយតារាកិត្តិយសចូលរួមក្នុងកម្មវិធីនេះ»។

កញ្ញា តែន លីណា (២៦ឆ្នាំ)
ជាអាជីវករលក់កាហ្វេក្នុងរាជធានីភ្នំពេញ

▲ វគ្គមានពិធីការីនីដែលមានបទពិសោធន៍យូរឆ្នាំគឺអ្នកនាង ខៀវ សានសាណា និងលោក អៀង វិច្ឆ័យ ជាអ្នកសម្របសម្រួលនឹងនាំអារម្មណ៍ប្រិយមិត្តអ្នកទស្សនាស្តុងអារម្មណ៍ជាមួយកម្មវិធី “V TALK Confession” !

BTV ទូរទស្សន៍ BTV

2.5M Followers

ប៉ុស្តិ៍ BTV ផ្សាយពិសេសអំពី ព័ត៌មានជាតិ អន្តរជាតិថ្មីៗ និងទាន់ហេតុការណ៍ រួមទាំងកម្មវិធីកីឡាពេញនិយមជាដើម ទទួលបានការទស្សនាច្រើននៅកម្ពុជាបច្ចុប្បន្ន។ BTV ជាស្ថានីយផ្សព្វផ្សាយដើរទាន់សម័យបច្ចេកវិទ្យា និងផ្តោតសំខាន់លើព័ត៌មានច្បាស់ការ។ ប្រជាពលរដ្ឋទូទៅអាចតាមដានកម្មវិធីទាំងអស់របស់ប៉ុស្តិ៍ BTV នេះតាមរយៈប្រព័ន្ធផ្សព្វផ្សាយពេញនិយមដូចជា៖ ហ្វេសប៊ុក យូធូប ឬអ៊ែប (កម្មវិធីទស្សនាទូរទស្សន៍តាមទូរសព្ទដៃ) និងតេលេក្រាមជាដើម។

▲កញ្ញា ដាវណ្ណ

កញ្ញា ដាវណ្ណ ជា អ្នកអាន និងអត្ថាធិប្បាយព័ត៌មានឆ្នើមប្រចាំទូរទស្សន៍ BTV

ផ្តើមចេញពីការស្រឡាញ់ និងចូលចិត្តស្តាប់វិទ្យុ ធ្វើឱ្យកញ្ញា ដាវណ្ណ សម្រេចចិត្តចាប់យកវិស័យព័ត៌មានជាអាជីព។ ដំបូងឡើយ កញ្ញាបានចូលបម្រើការជាអ្នកអានព័ត៌មាន ក្រោយពីខ្លួនត្រូវបានវិទ្យុក្នុងស្រុកមួយជ្រើសរើស ព្រោះទឹកដមសំឡេងល្អ សក្តិសមជាអ្នកអានព័ត៌មាន។ ការស្រឡាញ់ និងចូលចិត្តវិស័យនេះ បានធ្វើឱ្យកញ្ញា ដាវណ្ណ ធ្វើការងារនេះដោយមិនធុញណាយ និងបានអភិវឌ្ឍសមត្ថភាពខ្លួនជាបន្តបន្ទាប់ រហូតក្លាយជាអ្នកផលិតកម្មវិធីផ្សាយព័ត៌មានម្នាក់សម្រាប់ស្ថានីយ៍ទូរទស្សន៍ BTV ។

កញ្ញា ដាវណ្ណ លើកឡើងពីការយល់ឃើញផ្ទាល់ខ្លួនចំពោះសារព័ត៌មានដូច្នេះថា៖ “ពេលដែលសង្គមមួយកាន់តែអភិវឌ្ឍ វិស័យសារព័ត៌មានកាន់តែសំខាន់ ហើយវានឹងធ្វើឱ្យគុណភាព និងគុណតម្លៃរបស់អ្នកសារព័ត៌មានកាន់តែប្រសើរជាងមុន”។ ក្នុងន័យនេះ កញ្ញា បានពន្យល់បន្ថែមដូច្នេះថា៖«សង្គមកាន់តែអភិវឌ្ឍនឹងធ្វើឱ្យប្រជាពលរដ្ឋកាន់តែមានចំណេះដឹង និងកាន់តែយល់អំពីតម្លៃអ្វីទៅជាអត្ថប្រយោជន៍នៃសារព័ត៌មាន ហើយនៅពេលប្រជាពលរដ្ឋឱ្យតម្លៃទៅលើសារព័ត៌មាន នោះពលរដ្ឋនឹងចូលចិត្តតាមដាននូវព័ត៌មានទាំងឡាយណាដែលមានប្រយោជន៍សម្រាប់ពួកគាត់»។ បើប្រៀបធៀបកាលពីប្រមាណជាង ១០ឆ្នាំមុនកញ្ញា ដាវណ្ណ សង្កេតឃើញថា បច្ចុប្បន្ន អ្នកសារព័ត៌មានមានចំណេះដឹង និងវិជ្ជាជីវៈកាន់តែប្រសើរ ខណៈមានយុវជនកាន់តែច្រើនចាប់ផ្តើមសិក្សាក្នុងវិស័យសារព័ត៌មាននេះផងនោះ ក៏បានធ្វើឱ្យតម្លៃនៃការផ្សព្វផ្សាយព័ត៌មាននៅកម្ពុជា ត្រូវបានសាធារណជនទូទៅឱ្យតម្លៃកាន់តែខ្ពស់ជាងមុនផងដែរ។ កញ្ញា ដាវណ្ណៈ «នៅពេលសេដ្ឋកិច្ច និងសង្គមមានការរីកចម្រើន នោះវត្តមានរបស់អ្នកសារព័ត៌មាន និងការផ្តល់ព័ត៌មានជាក់លាក់ទៅកាន់សាធារណជន គឺកាន់តែសំខាន់!»។

Hang Meas HDTV

ក្រុមហ៊ុន ហង្សមាស

Hang Meas HDTV: 3.3 M Followers

Rasmey Hang Meas HDTV: 614K followers

ក្រុមហ៊ុន ហង្សមាស ត្រូវបានបង្កើតឡើងនៅដើមឆ្នាំ១៩៩០ ជាក្រុមហ៊ុនដំបូងគេទទួលសិទ្ធិចែកចាយផ្តាច់មុខរឿងភាគមកពីទីក្រុងហុងកុង និងប្រទេសសឹង្ហបុរី ផ្សាយជាភាសាខ្មែរ ទទួលការពេញនិយមខ្លាំងនៅកម្ពុជារហូតមក។ ក្រៅពីនោះ ក្រុមហ៊ុនហង្សមាស ក៏ល្បីល្បាញជាមួយនឹងការផលិតវីដេអូរឿងភាគខ្មែរ ចម្រៀង ខារ៉ាអូខេ និងកម្មវិធីសិល្បៈនានាក្នុងស្រុកផងដែរ។ នៅដើមឆ្នាំ២០១២ ស្ថានីយ៍ទូរទស្សន៍ “ហង្សមាស HDTV” ចេញផ្សាយផ្តោតចម្បងលើកម្មវិធីសិល្បៈកម្សាន្ត ខណៈកម្មវិធីព័ត៌មានពេលព្រឹក និងព័ត៌មានសង្គមក៏មានប្រជាប្រិយខ្ពស់ផងដែរ។ ដោយទទួលបានការគាំទ្រខ្លាំងត្រឹមរយៈពេលដ៏ខ្លី ក្រុមហ៊ុន ហង្សមាស បន្តបើកផ្សាយទូរទស្សន៍ “រស្មីហង្សមាស HDTV” ក្នុងឆ្នាំ២០១៤។

បច្ចុប្បន្ន ទូរទស្សន៍ហង្សមាស HDTV និង រស្មីហង្សមាស HDTV ជាស្ថានីយ៍ផ្សាយ ដែលមានសន្ទុះគាំទ្រខ្លាំងពីមហាជនទូទៅគ្រប់មជ្ឈដ្ឋាន។ វត្តមានរបស់តារាចម្រៀងល្បីៗដូចជា៖ អ្នកស្រី ឱក សុគន្ធកញ្ញា លោក ណុប ប៉ាយ៉ារិទ្ធ អ្នកស្រី ពេជ្រ សោភា លោក ឆន សុវណ្ណរាជ អ្នកស្រី សុគន្ធ នីសា ជាដើមធ្វើឱ្យក្រុមហ៊ុននេះកាន់តែល្បីល្បាញ ជាពិសេស ជាមួយកម្មវិធី Cambodian Idol និងកម្មវិធី The Voice Kids Cambodia ។

\ កម្មវិធី /
Cambodian Idol

TV រាល់ថ្ងៃអាទិត្យពីម៉ោង៩ដល់១០យប់ | 3.2M Followers

Cambodian Idol ជាកម្មវិធីប្រឡងចម្រៀងចាក់ផ្សាយជាផ្លូវការដំបូងនៅខែកក្កដា ឆ្នាំ២០១៥ លើកញ្ចក់ទូរទស្សហង្សមាស HDTV។ មកទល់បច្ចុប្បន្ន កម្មវិធីនេះបានប្រព្រឹត្តិទៅ៤រដូវកាល ដោយរដូវកាលទីមួយ ជ័យលេភីលេខ១បានទៅលើបេក្ខជន នី រតនា ខណៈរដូវកាលទី២ ដំណើរការក្នុងឆ្នាំ២០១៦ ម្ចាស់ជ័យលាភីលេខ១ គឺបេក្ខនារីឈ្មោះ ចន្ទម៉ានិច្ច។ដោយឡែកនៅរដូវកាលទី៣ កម្មវិធីនេះបានចាប់ផ្តើមប្រកួតវគ្គជម្រុះដំបូងនៅដើមឆ្នាំ២០១៨ ដោយជ័យលាភីលេខ១បានទៅលើបេក្ខជន គ្រី ថៃពៅ និងរដូវកាលទី៤ ទើបតែបានបញ្ចប់ទៅថ្មីៗនេះ ដែលក្នុងវគ្គជម្រុះផ្តាច់ព្រ័តក្នុងចំណោមបេក្ខជនទាំង៨រូប បានធ្វើឱ្យចំនួនអ្នកតាមដានទស្សនាកម្មវិធីផ្សាយបន្តផ្ទាល់ផ្ទុះកំណើនច្រើនជាង 754K ដោយក្នុងនោះសម្តេចនាយករដ្ឋមន្ត្រី ហ៊ុន សែន ក៏បានចូលរួមខមិនលើកទឹកចិត្តបេក្ខជនប្រឡងផងដែរ។ ជ័យលាភីលេខ១ សម្រាប់កម្មវិធី Cambodian Idol ឆ្នាំ២០២២ គឺបានទៅលើបេក្ខជន លឹម តិចម៉ែង។

ជ័យលាភីលេខ១ សម្រាប់កម្មវិធី Cambodian Idol ឆ្នាំ២០២២ ទទួលបានប្រាក់រង្វាន់ ១០០លានរៀល (25,000USD) និងត្រូវបានទទួលយកជាតារាចម្រៀងអាជីពប្រចាំក្រុមហ៊ុនផលិតកម្មរស្មីហង្សមាស។

▲ បេក្ខជនទាំង៨រូបក្នុងវគ្គប្រកួតផ្តាច់ព្រ័ត (រូបស្តាំទី១៖ លោក លឹម តិចម៉ែង)

\ ចំណាប់អារម្មណ៍អ្នកនិយមចូលចិត្តកម្មវិធី / Cambodian Idol

«នាងខ្ញុំបានស្គាល់កម្មវិធីនេះក្នុងឆ្នាំ២០១៩។ កម្មវិធីនេះ បើនិយាយក្នុងបរិបទស្រុកយើងវិញ គឺថ្មី ហើយប្លែក បុករួមទាំងការរៀបចំឆាកយ៉ាងល្អឯកទៀតផងនោះ ធ្វើឱ្យនាងខ្ញុំមានអារម្មណ៍ស្រស់ស្រាយ និងសប្បាយចិត្តពេលទៅទស្សនាផ្ទាល់ម្តងៗ។ នាងខ្ញុំផ្ទាល់ចាប់អារម្មណ៍ពិសេសត្រង់ចំណុចវគ្គ performance live show ដ្បិតមើលទៅមានការប្រកួតប្រជែងខ្លាំងដោយបេក្ខជននីមួយៗព្យាយាមដុសខាត់និងបង្ហាញសមត្ថភាពដើម្បីទទួលបានការចាប់អារម្មណ៍ពីមហាជន សម្រាប់ជាប់ទៅវគ្គបន្ទាប់»។ ក្នុងកម្មវិធី Cambodian Idol រដូវកាលទី៤ ដែលទើបចប់នៅចុងខែសីហាថ្មីៗនេះ កញ្ញា ស្រីណុច បានប្រាប់ពីបេក្ខជនដែលខ្លួនចូលចិត្តជាងគេនោះគឺ លោក លឹម តិចម៉ែង។ កញ្ញាយល់ឃើញថា លោក លឹម តិចម៉ែង ជាបេក្ខជនមានការខិតខំប្រឹងប្រែងខ្លាំង ចេះកំប្លែង មានចរិកសរសាយរាក់ទាក់ និងច្រៀងពីរោះជាងគេ។ កញ្ញា ស្រីណុច ក៏សង្កេតឃើញដែរថា សន្ទុះនៃការនិយមទស្សនាកម្មវិធី Cambodian Idol រដូវកាលទី៤ មានកំណើនច្រើនជាងរដូវកាលមុនៗ ហើយអ្នកដែលចូលចិត្តតាមដានកម្មវិធីនេះគឺមានគ្រប់វ័យ។

កញ្ញា អាន ស្រីណុច (២២ឆ្នាំ)
បុគ្គលិកក្រុមហ៊ុន រស់នៅរាជធានីភ្នំពេញ



កញ្ញា យូវនាថ បានតាមដានកម្មវិធី Cambodian Idol ចាប់តាំងពីទូរទស្សន៍ហង្សមាសចាក់ផ្សាយកម្មវិធីនេះរដូវកាលទី១ មក។ ជានិច្ចកាល កញ្ញាតែងតែតាមដានទស្សនាកម្មវិធីនេះ តាមរយៈការចាក់ផ្សាយបន្តផ្ទាល់ដោយមិនដែលអខានឡើយ ពោលគឺកញ្ញាតែងតែទស្សនាគ្រប់រដូវកាល និងគ្រប់សប្តាហ៍។ កញ្ញា យូវនាថ៖ «ជាការពិតណាស់ នាងខ្ញុំចាប់អារម្មណ៍សឹងតែគ្រប់ចំណុចរបស់កម្មវិធីនេះ ទាំងការរៀបចំតុបតែង ទាំងពិធីករ ក៏ដូចជាឈុតឆាកវិញ្ញាសា បុករួមទាំងគណៈកម្មការវាយតម្លៃដែលសុទ្ធតែជាតារាល្បីៗប្រចាំប្រទេសផងនោះ បានធ្វើឱ្យរូបនាងខ្ញុំពិតជាចាប់អារម្មណ៍កម្មវិធីនេះយ៉ាងខ្លាំង ហើយសម្រាប់រដូវកាលនេះ នាងខ្ញុំសង្កេតឃើញថាមានបេក្ខជនជាច្រើនដែលមានសមត្ថភាពខ្ពស់»។ កញ្ញា យូវនាថ ក៏បានលើកឡើងដែរថាកម្មវិធី Cambodian Idol នេះអាចធ្វើឱ្យអារម្មណ៍របស់មហាជនពុះកញ្ជ្រោលផ្ទុះសំណើចផង និងស្រក់ទឹកភ្នែកផងដែរ។ កញ្ញា៖ «និយាយឱ្យខ្លី ពេលបេក្ខជននីមួយៗបកស្រាយចម្រៀងនៅលើឆាកម្តងៗធ្វើឱ្យមហាជន ក៏ដូចជាទស្សនិកជនទស្សនាផ្ទាល់ សប្បាយ និងរំភើបជាខ្លាំង។ ប៉ុន្តែកំឡុងពេលប្រកាសលទ្ធផលវិញ កម្មវិធីធ្វើឱ្យទស្សនិកជនបែរជាមានអារម្មណ៍ក័យព្រួយទៅវិញ ព្រោះពួកគាត់បារម្ភខ្លាចបេក្ខជនដែលពួកគាត់គាំទ្រមិនអាចឆ្លងផុតទៅវគ្គបន្ទាប់»។

កញ្ញា អ៊ុន យូវនាថ (២២ឆ្នាំ)
គ្រូបង្រៀន រស់នៅរាជធានីភ្នំពេញ

កញ្ញាបានស្គាល់កម្មវិធី Cambodian Idol នេះតាំងពីខ្លួននៅវិទ្យាល័យ ដោយកញ្ញាធ្លាប់មានមិត្តភក្តិចូលរួមប្រឡងក្នុងកម្មវិធីនេះ។ ក្រោយមក កញ្ញាក៏បានតាមកម្មវិធីនេះជារៀងរាល់រដូវកាល និងរាល់សប្តាហ៍។ កញ្ញា ស្រីនាង បានបង្ហាញពីចំណាប់អារម្មណ៍របស់ខ្លួនចំពោះកម្មវិធីយ៉ាងដូច្នេះថា៖ «វាជាកម្មវិធីមួយដ៏អស្ចារ្យ ដ្បិតរាល់ពេលបានទស្សនាកម្មវិធីនេះ ធ្វើឱ្យនាងខ្ញុំមានអារម្មណ៍រំភើប។ ទាំងការរៀបចំ ទាំងសមត្ថភាពបេក្ខជន ចូលរួមប្រឡងពីមួយឆ្នាំទៅមួយឆ្នាំ នាងខ្ញុំមើលឃើញថាកាន់តែមានការរីកចម្រើន»។ កញ្ញា ស្រីនាង ក៏ជាអ្នកគាំទ្របេក្ខជន លឹម តិចម៉ែច ម្នាក់ផងដែរ។ កញ្ញា៖ «គាត់ជាបុគ្គលមួយរូបដែលខ្ញុំគោរពស្រឡាញ់ ព្រោះខ្ញុំមើលទៅគាត់ជាមនុស្សរួសរាយរាក់ទាក់ មានប្រជាប្រិយ ចេះដាក់ខ្លួន អ្វីកាន់តែពិសេសលើនេះទៀតនោះគឺ គាត់ច្រៀងពីរោះហើយចេះលេងហ្គីតាទៀត ចំណុចទាំងនេះហើយ ដែលអាចធ្វើឱ្យគាត់ក្លាយជា Idol របស់ខ្ញុំដោយមិនដឹងខ្លួន»។

កញ្ញា ជុំ ស្រីនាង (២២ឆ្នាំ)
គ្រូបង្រៀន រស់នៅក្នុងរាជធានីភ្នំពេញ

\កម្មវិធី /
The Voice Kids Cambodia

កម្មវិធី The Voice Kids Cambodia ក៏មានកេរ្តិ៍ឈ្មោះល្បីល្បាញ និងកំពុងទទួលការចាប់អារម្មណ៍ខ្លាំងពីមហាជនខ្មែរទូទៅដែរ។ នៅឆ្នាំ២០១៧ ស្ថានីយទូរទស្សន៍ ហង្សមាស HDTV បានឡើមចងតនិងចាក់ផ្សាយកម្មវិធីនេះជាលើកទីមួយ ដែលកាលនោះ ម្ចាស់ជ័យលាភីបានទៅលើ កុមារ៉ាឈ្មោះ ពេជ្រ ថៃ ហើយការប្រកួតជម្រុះចុងក្រោយផ្ទុះឡើងនូវចំនួនអ្នកតាមដានទស្សនាច្រើនពុំធ្លាប់មានពីមុនមក។ ចំណែកឯរដូវកាលទី២ នៅចុងឆ្នាំ២០១៨ ម្ចាស់ជ័យលាភីបានទៅលើកុមារ៉ា ទេព ពិសិដ្ឋ។ ដោយឡែករដូវកាលទី៣ ក្នុងឆ្នាំ២០២២ នេះ មិនទាន់ដឹងនរណាជាម្ចាស់ពានរង្វាន់រដូវកាលនេះទេ ព្រោះកម្មវិធីនេះកំពុងតែធ្វើការប្រកួតនៅឡើយ។

1.4 M Followers

▲ ផ្ទាំងផ្សាយកម្មវិធី The Voice Kids Cambodia

▶ទិដ្ឋភាពប្រកួតចម្រៀងរបស់កុមារ

«នេះជាលើកទីមួយដែលខ្ញុំមកទស្សនាផ្ទាល់ ហើយមានអារម្មណ៍សប្បាយរីករាយខ្លាំង។ មកផ្ទាល់គឺខុសគ្នាឆ្ងាយពីការទស្សនាតាមអនឡាញ យើងអាចស្រែកហៅសប្បាយរីករាយជាមួយមនុស្សនៅជុំវិញខ្លួន។ ខ្ញុំយល់ថាកម្មវិធីនេះជាកម្មវិធីប្រឡងចម្រៀងលំដាប់ថ្នាក់ពិភពលោកមួយដែលផ្តល់ឱកាសឱ្យក្មេងៗបង្ហាញសមត្ថភាពរបស់ពួកគាត់។ យ៉ាងណាមិញ នាងខ្ញុំក៏មានប្អូនប្រុសដែលជាបេក្ខជនឈ្មោះ វាសនា ធិណារាជ ចូលរួមប្រឡងក្នុងកម្មវិធីនេះផងដែរ។ បច្ចុប្បន្ន គាត់ប្រឡងដល់វគ្គ Battle Roundsហើយ»។

កញ្ញា វ៉ាសនា ចាន់នីកា (១៧ឆ្នាំ)
សិស្សវិទ្យាល័យ រស់នៅរាជធានីភ្នំពេញ

«នាងខ្ញុំជាអ្នកតាមដានកម្មវិធីនេះតាំងពីរដូវកាលទីមួយមកម្ល៉េះ ប៉ុន្តែមិនដែលបានមកទស្សនាផ្ទាល់ ហើយនេះជាលើកទីមួយដែលបានមកចូលរួមទស្សនាកម្មវិធីប្រឡងចម្រៀងលំដាប់ថ្នាក់ពិភពលោកបែបនេះ។ នៅពេលបានទស្សនាផ្ទាល់ ខ្ញុំមានអារម្មណ៍ថាសប្បាយ និងប្លែកខ្លាំង ដោយសារមកដល់ទីនេះយើងអាចស្តាប់ការបកស្រាយចម្រៀង និងស្រែកហៅជាមួយអ្នកដែលមកទីនេះដូចគ្នា។ មួយវិញទៀត ពេលបានមកមើលផ្ទាល់ គឺយើងទទួលបានអារម្មណ៍ពិសេស ដោយបានស្តាប់ចម្រៀងក្នុង Studio ដែលបិទជិត និងនៅក្នុងម៉ាស៊ីនត្រជាក់បែបនេះ គឺថាមកទស្សនាហើយចង់មកម្តងទៀត»។

កញ្ញា វង្ស អាយអេង (១៨ឆ្នាំ)
និស្សិត រស់នៅរាជធានីភ្នំពេញ

«The voice kids Cambodia ជាកម្មវិធីមួយដែលផ្តល់ឱកាសដល់ក្មេងៗគ្រប់រូបបានបញ្ចេញសមត្ថភាពរបស់ពួកគេទៅកាន់អ្នកគាំទ្រ ក៏ដូចជាមហាជនជាដើម។ នាងខ្ញុំបានតាមដានទស្សនាកម្មនេះ តាំងតែពីរដូវកាលទីមួយមកម្ល៉េះ ប៉ុន្តែមិនសូវបានមកទស្សនាផ្ទាល់ដូចពេលនេះទេ។ ការដែលបានមកទស្សនាផ្ទាល់បែបនេះពិតជាមានអារម្មណ៍សប្បាយរីករាយជាងការមើលតាមការផ្សាយបន្តផ្ទាល់ឆ្ងាយណាស់ ដ្បិតបានស្តាប់ការបកស្រាយចម្រៀងរបស់បេក្ខជននីៗមួយផ្ទាល់។ កាន់តែពិសេសទៀតនោះ ការមកទស្សនាកម្មវិធីនេះ វាក៏ជាការលម្ហែមួយ ដើម្បីបំបាត់ភាពតានតឹងផងដែរ ខណៈមនុស្សម្នារចម្រុះវ័យយ៉ាងច្រើនកុះករមកចូលរួមទស្សនា និងឃើញនូវកាយវិការយ៉ាងរស់រវើកក្នុងស្តានីយ៍ ធ្វើឱ្យនាងខ្ញុំហាក់មានអារម្មណ៍រំភើបមួយបែបទៀត នៅពេលដែលបានឃើញមនុស្សម្នាច្រើនបែបនេះ។ ជាមួយគ្នានេះ ពេលកម្មវិធីចាប់ផ្តើមយើងក៏បានឃើញវត្តមានរបស់គណៈកម្មការវាយតម្លៃដែលជាតារាល្បីៗនៅកម្ពុជាយើងផងនោះ កាន់តែធ្វើឱ្យនាងខ្ញុំមានអារម្មណ៍រំភើបថែមមួយកម្រិតទៀត»។

កញ្ញា ឈិន បញ្ញា (១៨ឆ្នាំ)
និស្សិតរស់នៅរាជធានីភ្នំពេញ

▲ រាល់កម្មវិធី The Voice Kids Cambodia មានយុវជនជាច្រើនទៅទស្សនាផ្ទាល់

▲ ស្ថានភាពផ្សព្វផ្សាយកម្មវិធី The Voice Kids Cambodia នៅមុខផ្សារទំនើប AEON2

ក្រុមហ៊ុនទូរទស្សន៍ពេញនិយមដទៃ

ដើម្បីទទួលបានការគាំទ្រពីអ្នកទស្សនា ក្រុមហ៊ុនទូរទស្សន៍ដទៃកំពុងស្វះស្វែងផលិតកម្មវិធីទាក់ទាញផ្សេងៗ។ យើងខ្ញុំសូមណែនាំត្រួសៗពីកម្មវិធីទូរទស្សន៍ទាំងនោះ។

ទូរទស្សន៍ PNN

2.1 M Followers

PNN មានឈ្មោះពេញ «People National Network» ជាស្ថានីយទូរទស្សន៍ ដែលមានទំហំធំជាងគេបង្អស់នៅកម្ពុជា និងមានថវិការិនិយោគប្រមាណ ៤០លានដុល្លារអាមេរិក។ PNN បានចាប់ផ្តើមដំណើរការផ្សាយសាកល្បងលើកដំបូងកាលពីខែកក្កដា ឆ្នាំ២០១៥។ ទូរទស្សន៍ PNN ផលិតកម្មវិធីព័ត៌មាន និងកម្សាន្តមានដូចជា៖ ការប្រគុំតន្ត្រីសម័យទំនើប។ កម្មវិធីសម្តែងសមត្ថភាពកុមារ និងកម្មវិធីចម្រៀង The Wall Song ជាដើមកំពុងទទួលការចាប់អារម្មណ៍ខ្លាំងពីអ្នកទស្សនា។ PNN ក៏បានលើកស្ទួយវិស័យភាពយន្តភាគខ្មែរ ដោយចំណាយទុនយ៉ាងច្រើនសន្ធឹកសន្ធាប់ផលិតរឿងភាគខ្មែរ ដែលមានគុណភាព និងកំពុងទទួលការពេញនិយម។

▲ កម្មវិធីសម្តែងទេពកោសល្យកុមារ

▲ឈុតមួយនៃរឿងភាគខ្មែរចាក់ផ្សាយលើកញ្ចក់ទូរទស្សន៍ PNN

«នាងខ្ញុំចូលចិត្តមើលប៉ុស្តិ៍ PNN ព្រោះសំបូររឿងភាគខ្មែរ និងចៃណ្ណមើល។ ជាទូទៅ ខ្ញុំបើកមើលនៅម៉ោងពេលបាយល្ងាច តរហូតដល់ពេលចូលគេង ព្រោះគេចាក់បញ្ចាំងរឿងភាគថៃនិងខ្មែរល្អៗមើលហើយប៉ុស្តិ៍ហ្នឹងមើលច្បាស់ជាងប៉ុស្តិ៍ដទៃទៀត»

បងស្រី ឥន្ទ ញ៉ានពុទ្ធាវី (៥៣ឆ្នាំ)
អាជីវករ រស់នៅភ្នំពេញ

ទូរទស្សន៍ TV5

947K Followers

ស្ថានីយទូរទស្សន៍កងយោធពលខេមរភូមិន្ទ ប៉ុស្តិ៍លេខ៥ បានចាប់ផ្តើមដំណើរការផ្សព្វផ្សាយចាប់តាំងពីខែវិច្ឆិការ ឆ្នាំ១៩៩៥។ មានផ្សាយព័ត៌មានក្នុងនិងក្រៅប្រទេស សិល្បៈកម្សាន្ត កីឡាជាដើម។ ជាពិសេស បច្ចុប្បន្ន ស្ថានីយទូរទស្សន៍ប៉ុស្តិ៍លេខ៥ កំពុងផលិតរឿងភាគខ្មែរ និងចាក់ផ្សាយរឿងភាគថៃ ចិន និងឥណ្ឌាល្បីៗមួយចំនួន។ កម្មវិធីផ្សាយពីការប្រកួតកីឡាប្រដាល់ខ្មែរនៅចុងសប្តាហ៍ក៏ពេញនិយមខ្លាំងដែរ។ បច្ចុប្បន្ន ការប្រកួតដណ្តើមខ្សែក្រវាត់ពានរង្វាន់ “សម្តេចពិជ័យសេនា ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងការពារជាតិ” កំពុងទទួលការពេញនិយម។

▲ ឈុតរឿងភាគខ្មែរចាក់ផ្សាយលើកញ្ចក់ទូរទស្សន៍ TV5

«បើនិយាយពីការទស្សនាប៉ុស្តិ៍ទូរទស្សន៍វិញ ខ្ញុំចូលចិត្តប៉ុស្តិ៍ BTV សម្រាប់ការមើលកីឡាបាល់ទាត់ក្នុងស្រុក។ ហើយប៉ុស្តិ៍ TV5 ខ្ញុំចូលចិត្តមើលព័ត៌មានកីឡាជាតិ និងអន្តរជាតិ ដោយសារខ្ញុំពេញចិត្តនឹងការអធិប្បាយរបស់ពិធីករគឺ លោក ហារ ង៉ែត។ រីឯប៉ុស្តិ៍ PNN វិញ ខ្ញុំចូលចិត្តមើលភាពយន្តខ្មែរ និងថៃ»

យុវជន គុណា ស៊ាងអូន (១៨ឆ្នាំ)
សិស្សវិទ្យាល័យ រស់នៅខេត្តតាំងឃ្មុំ

▲ កម្មវិធីផ្សាយព័ត៌មានពេលព្រឹកប៉ុស្តិ៍ TV5

ទូរទស្សន៍ជាតិកម្ពុជា TVK

ជាទូរទស្សន៍រដ្ឋតែមួយគត់នៅកម្ពុជា ពេញនិយមជាមួយការផ្សព្វផ្សាយព័ត៌មានជាតិ អន្តរជាតិ ព័ត៌មានកីឡា និងកម្មវិធីអប់រំមួយចំនួន។ បច្ចុប្បន្នក៏កំពុងពង្រឹងការផ្សាយតាមទំព័រហ្វេសប៊ុកផងដែរ។

831K Followers

តើអ្នកចូលចិត្តទស្សនាទូរទស្សន៍តាមកញ្ចក់ទូរទស្សន៍ ឬតាមទូរសព្ទស្មាតហ្វូន?

ដោយសារមានចំនួនអ្នកនិយមប្រើបណ្តាញសង្គមលើប្រព័ន្ធអ៊ីនធឺណិតកើនឡើងច្រើនលើសលប់នាពេលបច្ចុប្បន្ន បានធ្វើឱ្យចំនួនអ្នកទស្សនាកម្មវិធីទូរទស្សន៍តាមកញ្ចក់ទូរទស្សន៍នៅតាមផ្ទះមានចំនួនថយចុះគួរឱ្យកត់សម្គាល់។ យើងសង្កេតឃើញថា វប្បធម៌នៃការទស្សនាកម្មវិធីទូរទស្សន៍ជាគ្រួសារ ត្រូវបានបាត់បង់បន្តិចម្តងៗក្រោមវត្តមាននៃការរីកចម្រើនលើវិស័យបច្ចេកវិទ្យា និងការនិយមប្រើប្រាស់ទូរសព្ទដៃស្មាតហ្វូនភ្ជាប់អ៊ីនធឺណិត។

«បច្ចុប្បន្នគ្រួសារនាងខ្ញុំពុំសូវមានអ្នកបើកទូរទស្សន៍មើលដូចមុនទេ ទាំងនាងខ្ញុំនិងពួកគាត់ភាគច្រើនបានងាកមកមើលទូរសព្ទច្រើនជាង។ សម្រាប់នាងខ្ញុំ គឺសឹងតែមិនដែលនឹកឃើញទៅបើកទូរទស្សន៍មើលទេ គឺមើលតែតាមទូរសព្ទព្រោះវាងាយស្រួលនិងអាចរើសកម្មវិធីខ្លួនចូលចិត្តមើលពេលណាក៏បាន។ ខ្ញុំឃើញថាកម្មវិធីចាក់ផ្សាយក្នុងទូរទស្សន៍ភាគច្រើនក៏មាននៅលើទូរសព្ទដូចគ្នាដែរ។ ទាក់ទងនឹងស្ថានភាពមើលទូរទស្សន៍របស់អ្នករស់នៅក្បែរៗកន្លែងនាងខ្ញុំរស់នៅវិញ នាងខ្ញុំសង្កេតឃើញថានៅមានអ្នកមើលខ្លះៗដែរដោយភាគច្រើនពួកគាត់ជាមនុស្សចាស់ចូលចិត្តមើលព័ត៌មាន រឿងភាគ និងកីឡាប្រដាល់ជាដើម។ យ៉ាងណាមិញក្មេងតូចៗក៏ចូលចិត្តមើលតុក្កតាក្នុងទូរទស្សន៍ដែរ»។

កញ្ញា សោភា លីណា (២១ឆ្នាំ)
អ្នកសារព័ត៌មាន រស់នៅរាជធានីភ្នំពេញ

លោក វាសនា ខានមើលទូរទស្សន៍ប្រមាណ ៦ ទៅ ៧ឆ្នាំមកហើយ ព្រោះគិតថាកម្មវិធីផ្សាយសំខាន់ៗរបស់ប៉ុស្តិ៍ទូរទស្សន៍ ត្រូវបានគេយកមកផ្សាយលើឆានែលហ្វេសប៊ុក និងយូធូបរបស់ប៉ុស្តិ៍ទូរទស្សន៍ទាំងនោះ។ ម្យ៉ាងទៀត លោកមានកម្មវិធីអ៊ែរ PPCTV សម្រាប់មើលប៉ុស្តិ៍ទូរទស្សន៍លើទូរសព្ទដៃដោយពុំគិតថ្លៃ។ លោកវាសនា៖ «ទាំងខ្ញុំរួមទាំងគ្រួសារខ្ញុំ និងអ្នករស់នៅជិតខាងផងដែរ ខ្ញុំសង្កេតឃើញថាពួកគាត់លែងសូវមើលទូរទស្សន៍នៅតាមផ្ទះហើយ គឺភាគច្រើនបំផុតមើលតែតាមទូរសព្ទស្មាតហ្វូនរៀងៗខ្លួនវិញម្តង។ សម្រាប់តាមដានកម្មវិធីព័ត៌មាន គេនិយមស្តាប់តែវិទ្យុ និងការផ្សាយតាមឆានែលហ្វេសប៊ុករបស់ប៉ុស្តិ៍ទូរទស្សន៍ដែលគេចូលចិត្តទេ។ ម្យ៉ាងទៀតឥឡូវគេនិយមប្រើទូរទស្សន៍ស្មាតធីវីវិញ ដើម្បីមើលកម្មវិធីផ្សាយផ្សេងៗចេញពីទូរសព្ទដៃមើលជុំគ្នានៅផ្ទះ ព្រោះវាមានកម្មវិធីមើលច្រើនភ្ជាប់នឹងអ៊ីនធឺណិត»។

លោក ឃោ វាសនា (៣៧ឆ្នាំ)
មន្ត្រីរាជការ រស់នៅក្រុងសៀមរាប

«ខ្ញុំខានមើលទូរទស្សន៍រយៈពេលជាង ២ឆ្នាំមកហើយ។ កាលពីមុនធ្លាប់ភ្ជាប់បណ្តាញទូរទស្សន៍ខ្សែកាបដើម្បីទស្សនាដែរ តែដោយសារមានកម្មវិធីចាក់ផ្សាយដដែលៗ មិនសូវមានអ្វីថ្មីទើបប្តូរមកទិញអង់តែន DTV ដើម្បីតំឡើងមើលវិញម្តងព្រោះមិនបាច់ចាំបង់ថ្លៃសេវាខ្សែកាបប្រចាំខែ។ យ៉ាងណាមិញ ព្រោះប៉ុស្តិ៍មើលតាម DTV បច្ចុប្បន្ន ពុំសូវមានកម្មវិធីទស្សនាថ្មី និងមិនសូវល្អមើល ធ្វើឱ្យក្មេងៗបែរមកចាប់អារម្មណ៍នឹងការមើលកម្មវិធីលើបណ្តាញសង្គមច្រើនជាងមើលប៉ុស្តិ៍ទូរទស្សន៍នៅផ្ទះវិញ។ ដោយសារក្មេងៗមានទូរសព្ទស្មាតហ្វូន ដូច្នេះពួកគេមើលកម្មវិធីនានាតាមហ្វេសប៊ុក និងយូធូបច្រើន ហើយឥឡូវលែងមើលទូរទស្សន៍ហើយ ជាពិសេសប្រមាណជាង២ឆ្នាំទៅនេះ»។

លោក ណុប វិសិទ្ធ (៨៣ឆ្នាំ)
វេជ្ជបណ្ឌិត រស់នៅខេត្តសៀមរាប

«តាំងពីខ្ញុំត្រឡប់ពីប្រទេសជប៉ុនមករស់នៅស្រុកខ្មែរវិញកាលពី៨ឆ្នាំមុន ខ្ញុំពុំដែលមើលប៉ុស្តិ៍ទូរទស្សន៍ខ្មែរតាមកញ្ចក់ទូរទស្សន៍ទេ។ ម្តងកាល ខ្ញុំមើលតែកម្មវិធីកំប្លែងគេចែករំលែកតាមហ្វេសប៊ុកប៉ុណ្ណោះ។ ជាទូទៅ ខ្ញុំមើលតែកម្មវិធីផ្សាយព័ត៌មានជាភាសាជប៉ុន តាមឆានែលយូធូបនិងហ្វេសប៊ុករួមទាំងកម្មវិធីអប់រំបង្កើនចំណេះដឹងផ្សាយលើយូធូបប៉ុណ្ណោះ។ កម្មវិធីផ្សាយរបស់ប៉ុស្តិ៍ទូរទស្សន៍ខ្មែរ និយាយតាមត្រង់ គឺខ្ញុំកម្រមើលណាស់»។

លោក គុយ គុលា (៣៦ឆ្នាំ)
វិស្វករក្រុមហ៊ុនសាងសង់ផ្លូវថ្នល់ បម្រើការនៅខេត្តបាត់ដំបង

«ចប្ចុប្បន្ន គេមិនសូវចាប់អារម្មណ៍មើលទូរទស្សន៍ទេ ព្រោះគេចូលចិត្តមើលទូរសព្ទជាង។ ពីមុនដូចយើងដឹងអ៊ីចឹង កាលពីមិនទាន់មានទូរសព្ទទំនើបដូចឥឡូវ គឺមានតែទូរទស្សន៍ទេដែលគេអាចមើលព័ត៌មានឬមើលរឿងភាគបាន។ តែជាក់ស្តែង ឥឡូវនេះវិញ ទូរទស្សន៍សឹងតែទុកចោលហើយគ្មានអ្នកមើលទេ សូម្បីតែមនុស្សចាស់ក៏មានទូរសព្ទទំនើបប្រើដែរ ដូច្នេះបានអីមើលទូរទស្សន៍ទៀត! ណាមួយឥឡូវទំនើបណាស់ បើគេចង់មើលទូរទស្សន៍ក៏អាចមើលក្នុងទូរសព្ទបានដូចគ្នា។ ខ្ញុំសង្កេតឃើញថាបច្ចុប្បន្នអ្នករស់នៅក្បែរៗខ្ញុំ គេមិនសូវមើលទូរទស្សន៍ទេ ដូចនិយាយពីខាងដើមអ៊ីចឹង ទូរសព្ទមានកម្មវិធីកម្សាន្តច្រើនសម្បូរបែបចង់មើលអីក៏បាន ហើយងាយស្រួលទៀត»។

កញ្ញា ស៊ីយ សុម៉ាឌុត (២៣ឆ្នាំ)
អាជីវករលក់ដូរ រស់នៅខេត្តកំពង់ចាម

«ខ្ញុំខានមើលទូរទស្សន៍តាំងពីអំឡុងឆ្នាំ២០១៥ បន្ទាប់ពីចូលសាកលវិទ្យាល័យ ព្រោះត្រូវចំណាយពេលច្រើនលើការសិក្សាស្រាវជ្រាវនៅសាលា និងការងារក្រៅម៉ោង។ ជាទូទៅ ខ្ញុំតាមដានមើលការផ្សាយរបស់ក្រុមហ៊ុន ហង្សមាស ក្នុងកម្មវិធីប្រឡងចម្រៀងល្បីៗដូចជា "Cambodia Idol" ឬ "The Voice Kids Cambodia" ជាដើមតែប៉ុណ្ណោះ ហើយមើលតែតាមទូរសព្ទដៃទៀត។ យ៉ាងណាមិញ សម្រាប់អ្នកផ្ទះខ្ញុំវិញ ជាពិសេស ប្អូនស្រី និងឱពុកម្តាយខ្ញុំ គឺពួកគាត់នៅតែមើលប៉ុស្ត៍ទូរទស្សន៍ភាគច្រើននៅឡើយ គឺមើលកម្មវិធីកម្សាន្តដូចជា៖ កំប្លែង ការប្រឡងចម្រៀង និងរឿងភាគជាដើម។ពួកគាត់មើលភាគច្រើននៅម៉ោងពេលបាយល្ងាចនិងមុនចូលគេងជារៀងរាល់ថ្ងៃ»។ លោក ណារិទ្ធ ក៏បានលើកឡើងទៀតថា ដើម្បីអប់រំចិត្ត និងទទួលបានចំណេះដឹងសកលបន្ថែម លោកតែងតែទស្សនាកម្មវិធីអប់រំខ្លីៗលើឆាណែលហ្វេសប៊ុក ដែលពេញនិយមរបស់លោកគ្រូ គូ សុភាព និងកម្មវិធី "Nas Daily" ជាដើមផងដែរ។

លោក សេង ណារិទ្ធ (២៦ឆ្នាំ)
បុគ្គលិកក្រុមហ៊ុន រស់នៅក្រុងសៀមរាប

«ខ្ញុំមើលប៉ុស្ត៍ទូរទស្សន៍ជារៀងរាលថ្ងៃ។ ប៉ុស្ត៍ដែលតែងតែបើកមើលមានប៉ុស្ត៍ My TV, CTN និង PNN។ ហើយម្តងម្កាលក៏មានប៉ុស្ត៍ TV5 ផងដែរ។ ក្នុងចំណោមប៉ុស្ត៍ទាំងនោះ ខ្ញុំចូលចិត្តតាមដានរឿងភាគខ្មែរ និងថៃរបស់ប៉ុស្ត៍ PNN ចន្លោះម៉ោង ៧ ទៅ ៩ ល្ងាចជាងគេ ព្រោះគេចាក់រឿងល្អមើលច្រើន។ ប៉ុស្ត៍ផ្សេងៗ បើកចោលដើម្បីមើលកម្មវិធីកំប្លែង ប្រដាល់ ឬចម្រៀងប៉ុណ្ណោះ»។ បងស្រី សេរី បានតម្លើងអង់តែង DTV តម្លៃ ៩០ដុល្លាដើម្បីមើលប៉ុស្ត៍ទូរទស្សន៍ទាំងនោះ ហើយក៏សង្កេតឃើញថានៅក្នុងភូមិរបស់ខ្លួន មានអ្នកតាមដានមើលប៉ុស្ត៍ទូរទស្សន៍នៅតាមផ្ទះ នៅមានចំនួនច្រើននៅឡើយទេ។

បងស្រី ឈឹម សេរី (៤២ឆ្នាំ)
អាជីវករ រស់នៅស្រុកពពេល ខេត្តសៀមរាប

កម្មវិធីទស្សនាប៉ុស្ត៍ទូរទស្សន៍កំពុងផ្សាយផ្ទាល់

គេអាចទាញយកអេឃិប PPCTV និង One Tv Plus ដោយពុំគិតថ្លៃដើម្បីទស្សនាកម្មវិធីផ្សាយបន្តផ្ទាល់របស់ស្ថានីយ៍ទូរទស្សន៍ពេញនិយមទាំងក្នុងនិងក្រៅស្រុក។

PPCTV អេនឌីប Anywhere

One TV+Plus

ទិន្នន័យអង្កេតការអំពីស្ថានភាព

ទស្សនាកម្មវិធីសោតទស្សន៍

បច្ចុប្បន្ន ចំនួនអ្នកប្រើប្រាស់បណ្តាញសង្គមតាមទូរសព្ទស្មាតហ្វូនមានកាន់តែច្រើនឡើងៗ។ ការទស្សនាកម្មវិធីទូរទស្សន៍តាមទូរសព្ទដៃស្មាតហ្វូន ក៏ហាក់មានចំនួនកាន់តែកើនឡើងដែរ។ បុគ្គលិកទស្សនាវដ្តីញញឹម បានចុះសាកសួរនិស្សិត (៦៦នាក់) និងពលរដ្ឋទូទៅ (៥០នាក់) រស់នៅរាជធានីភ្នំពេញអំពីស្ថានភាពតាមដានកម្មវិធីទូរទស្សន៍តាមកញ្ចក់ទូរទស្សន៍ និងការផ្សាយលើបណ្តាញសង្គម ធ្វើឡើងនាអំឡុងខែវិច្ឆិកា ឆ្នាំ២០២២កន្លងទៅ ដោយទទួលបាននូវទិន្នន័យដូចខាងក្រោម។

របៀបមើលតារាង៖ តួលេខខាងឆ្វេងជាភាគរយពីចម្លើយនិស្សិត៦៦នាក់ — ខាងស្តាំជាភាគរយពីចម្លើយពលរដ្ឋ៥០នាក់

១. តើបច្ចុប្បន្នអ្នកនៅទស្សនាទូរទស្សន៍តាមកញ្ចក់ទូរទស្សន៍ដែរ ឬទេ?

	(និស្សិត—ពលរដ្ឋទូទៅ)
ក.នៅទស្សនានៅឡើយ	(20% — 62%)
ខ. ខានទស្សនា ១ ទៅ ២ឆ្នាំ	(26% — 20%)
គ. ខានទស្សនា ៣ ទៅ ៤ឆ្នាំ	(27% — 14%)
ឃ. ខានទស្សនាលើសពី ៥ឆ្នាំ	(27% — 4%)

២. ជាទូទៅ តើអ្នកទស្សនាទូរទស្សន៍តាមមធ្យោបាយណា?

ក. តាមកញ្ចក់ទូរទស្សន៍	(36% — 26%)
ខ. តាមទូរសព្ទដៃ	(40% — 10%)
គ. ទាំងទូរទស្សន៍ និងទូរសព្ទដៃ	(24% — 64%)

៣. ក្នុងចំណោមស្ថានីយ៍ទូរទស្សន៍ខាងក្រោមនេះ តើអ្នកចូលចិត្តទស្សនាប៉ុស្តិ៍ណាខ្លះ? (អាចរើសបានលើសពី១ចម្លើយ)

ក. ហង្សមាស (ឬស្មើហង្សមាស)	(61% — 68%)
ខ. ក្រុមហ៊ុន CBS (CTN, MYTV, CNC)	(21% — 24%)
គ. បាយ័ន (ឬBTV)	(21% — 48%)
ឃ. ភីអិនអិន (PNN)	(44% — 44%)
ង. ទូរទស្សន៍ប៉ុស្តិ៍លេខ ៥ (TV5)	(5% — 52%)
ច. ទទក (ឬTVK2)	(9% — 8%)
ឆ. ពុំចាប់អារម្មណ៍ប៉ុស្តិ៍ណាមួយជាពិសេសទេ	(0% — 0%)

៤. តើអ្នកចូលចិត្តមើលកម្មវិធីប្រភេទណា?

ក. កម្សាន្ត (ភាពយន្ត កំប្លែង តន្ត្រីជាដើម)	(85% — 44%)
ខ. អប់រំ	(23% — 26%)
គ. ព័ត៌មាន	(21% — 88%)
ឃ. កីឡា	(18% — 56%)

៥. តើអ្នក ឬក្រុមគ្រួសាររបស់អ្នកទស្សនាប៉ុស្តិ៍ទូរទស្សន៍ដោយប្រព័ន្ធបែបណា?

ក. ប្រើកម្មវិធីអ៊ែបតតបង់ប្រាក់ (PPCTV, One Tv Plus និង eRadio and TVជាដើម)	(50% — 10%)
ខ. ប្រើកម្មវិធីអ៊ែបបង់ប្រាក់ដើម្បីទស្សនា	(6% — 0%)
គ. មើលតាមផ្កាយរណបឌីជីថល (DTV)	(30% — 40%)
ឃ. មើលតាមបណ្តាញក្រុមហ៊ុនខ្សែកាបឯកជន	(27%— 64%)

៦. តើអ្នកចូលចិត្តទស្សនាទូរទស្សន៍ជាលក្ខណៈគ្រួសារ ឬ ចូលចិត្តមើលតែឯង?

ក. ចូលចិត្តទស្សនាជាមួយគ្រួសារ	(70% — 80%)
ខ. ចូលចិត្តទស្សនាម្នាក់ឯង	(30% — 20%)

៧. បច្ចុប្បន្ន តើអ្នកគិតថាខ្លួនមើលកម្មវិធីទូរទស្សន៍តាមកញ្ចក់ទូរទស្សន៍នៅផ្ទះជាមួយគ្រួសារ ញឹកញាប់ដែរឬទេ?

ក. ញឹកញាប់	(11% — 30%)
ខ. មើលខ្លះៗដែរ	(20% — 38%)
គ. ម្តងម្កាល	(44% — 32%)
ឃ. មិនដែលសោះ	(25% — 0%)

● ស្ថានភាពទស្សនាកម្មវិធីផ្សាយលើបណ្តាញសង្គមក្រៅពីកម្មវិធីទូរទស្សន៍

១. តើអ្នកចូលចិត្តទស្សនាការផ្សាយកម្មវិធីនានាលើបណ្តាញសង្គម (ហ្វេសប៊ុក យូធូបជាដើម) ដែរឬទេ?

ក. ចូលចិត្ត	(42% — 44%)
ខ. ចូលចិត្តខ្លះដែរៗ	(56% — 56%)
គ. មិនចូលចិត្ត (អាចរំលងសំណួរទី២ខាងក្រោម)	(2%—0%)

២. ប្រសិនបើចូលចិត្ត តើកម្មវិធីបែបណាដែលអ្នកតែងតែទស្សនា? (អាចរើសបានលើសពី១ចម្លើយ)

ក. ការសម្តែងប្លែកៗ	(21% — 44%)
ខ. វីដេអូខ្លីបែបអប់រំ	(33% — 28%)
គ. Video Vlog	(53% — 4%)
ឃ. Video Review (អាហារ បច្ចេកវិទ្យា ផលិតផលអ្វីមួយ កន្លែងកម្សាន្តជាដើម)	(58% — 4%)
ង. ការសម្រាយរឿង	(21% — 2%)
ច. កំប្លែងខ្លីៗ	(38% — 52%)
ឆ. កម្មវិធីកីឡា	(18% — 58%)
ជ. ព័ត៌មាន	(29% — 86%)

៣. តើអ្នកមានស្គាល់ក្រុមបង្កើតនិងសម្តែងវីដេអូខ្លីតាម FACEBOOK ឬ YouTube, ផេកតារាល្បីៗ និងផេកផ្សាយពីតីមានអនឡាញ ដែលមានផ្សព្វផ្សាយលើបណ្តាញសង្គមណាមួយដែរ ឬទេ?

ក. មិនមានស្គាល់ទេ	(55% — 90%)
ខ. មានស្គាល់	(45% — 10%)

៤. តើអ្នកយល់ឃើញណាចំពោះកម្មវិធីផ្សព្វផ្សាយនៅលើបណ្តាញសង្គមបច្ចុប្បន្ន បើធៀបនឹងកម្មវិធីចាក់ផ្សាយរបស់ទូរទស្សន៍?

ក. ទាក់ទាញខ្លាំង	(29% — 26%)
ខ. ទាក់ទាញខ្លះដែរ	(68% — 70%)
គ. មិនទាក់ទាញទេ	(3% — 4%)

ត្រួសៗអំពីដើមកំណើតផ្សាយទូរទស្សន៍



ឆ្នាំ១៩៦៦ ជាឆ្នាំដែលប្រទេសកម្ពុជាមានស្ថានីយទូរទស្សន៍ដំបូងគេបំផុត និងជាឆ្នាំដែលទូរទស្សន៍ជាតិកម្ពុជាបានចាប់កំណើតឡើង។ តែជាអកុសល ស្ថានីយទូរទស្សន៍មួយនេះ ត្រូវរងការខូតខាតទាំងស្រុងនៅក្នុងឆ្នាំ១៩៧៥ ដោយសារភ្លើងសង្គ្រាមនាសម័យខ្មែរក្រហម។ តែជាការប្រសើរដែរ ព្រោះនៅក្នុងកំឡុងឆ្នាំ១៩៧៩ ស្ថានីយទូរទស្សន៍ជាតិកម្ពុជាបានចាប់ផ្តើមដំណើរការជាថ្មី ដោយមានលទ្ធភាពចាក់ផ្សាយកម្មវិធីនានាត្រឹមតែ៨ម៉ោងក្នុងមួយថ្ងៃប៉ុណ្ណោះ។ ដោយមានការប្រែប្រួលជាបន្តបន្ទាប់ នៅដើមខែធ្នូ ឆ្នាំ១៩៨៣ ស្ថានីយទូរទស្សន៍ជាតិកម្ពុជា ត្រូវបានស្ថាបនាឡើងវិញ ទាំងធនធានមនុស្ស និងសម្ភារៈ។

ដោយឡែក នៅក្នុងឆ្នាំ១៩៨៦ ស្ថានីយទូរទស្សន៍ជាតិកម្ពុជា បានទទួលជំនួយពីរដ្ឋាភិបាលជប៉ុន តាមរយៈការបំពាក់ឧបករណ៍ទំនើបទាន់សម័យ។ ក្រោយមក ទូរទស្សន៍ជាតិកម្ពុជាអាចពង្រីកវិសាលភាពការចាក់ផ្សាយប្រចាំថ្ងៃពី៨ម៉ោងរហូតដល់១៨ម៉ោងក្នុងមួយថ្ងៃ និងពង្រឹងប្រព័ន្ធចែកផ្សាយរហូតដល់១២៦ប្រទេសតាមរយៈផ្កាយរណប។ គួរបញ្ជាក់ផងដែរ នៅក្នុងកំឡុងឆ្នាំ១៩៨៦ ប្រទេសកម្ពុជាមានស្ថានីយទូរទស្សន៍ទាំងអស់សរុប ១៥ស្ថានីយ ដែលក្នុងនោះមានស្ថានីយផ្សាយបន្តផ្ទាល់របស់វៀតណាម ទូរទស្សន៍បារាំង និងស្ថានីយផ្សាយបន្តតាមតំបន់។

ក្រោយភ្លើងសង្គ្រាមរ៉ាំរ៉ៃនៅកម្ពុជាបានរលត់ផុតទៅ វិស័យទូរគមនាគមន៍បានរីកចម្រើនជាបន្តបន្ទាប់។ ជាពិសេស នៅឆ្នាំ២០១២ ការផ្សព្វផ្សាយទូរទស្សន៍មានការប្រកួតប្រជែងខ្លាំង ដោយមានការបង្កើតស្ថានីយថ្មីមួយចំនួន ហើយស្ថានីយទូរទស្សន៍ដែលមានវត្តមានហើយនោះក៏បានបង្កើតកម្មពិធីចាក់ផ្សាយថ្មីៗ ប្លែកៗដើម្បីប្រកួតប្រជែងជាមួយស្ថានីយដទៃទៀត។ ទោះបីជានៅក្នុងឆ្នាំ២០១២ វិស័យទូរទស្សន៍មានការប្រកួតប្រជែងខ្លាំងក៏ពិតមែន ប៉ុន្តែនៅអំឡុងឆ្នាំ២០១៣ ការប្រើប្រាស់ទូរសព្ទដៃស្មាតហ្វូន និងអ៊ីនធឺណិតកើនឡើងយ៉ាងគំហុកនៅកម្ពុជានាំឱ្យមានកំណើនអ្នកទស្សនាប៉ុស្តិ៍ទូរទស្សន៍តាមទូរសព្ទដៃកើនឡើងច្រើនជាហូរហែ។ គិតត្រឹមឆ្នាំ២០២០ មានប្រជាជនខ្មែរប្រមាណជាង១៦លាននាក់ប្រើប្រាស់អ៊ីនធឺណិតដែលក្នុងនោះអ្នកប្រើបណ្តាញសង្គមហ្វេសប៊ុកមានរហូតដល់ប្រមាណ ១០,៩ លាននាក់។

សន្ទុះអ្នកទស្សនាកម្មវិធីផ្សាយតាមបណ្តាញសង្គម និងស្មាតហ្វូន

ដោយសារមានចំនួនអ្នកនិយមប្រើបណ្តាញសង្គមលើប្រព័ន្ធអ៊ីនធឺណិតកើនឡើងច្រើននាពេលបច្ចុប្បន្ន បានធ្វើឱ្យចំនួនអ្នកទស្សនាកម្មវិធីទូរទស្សន៍នៅផ្ទះមានចំនួនថយចុះ។ ជាទូទៅ នៅប្រមាណជា ១៥ឆ្នាំមុន ប្រជាជនខ្មែរមានទម្លាប់ទស្សនាប៉ុស្តិ៍ទូរទស្សន៍ជុំគ្នាតាមគេហដ្ឋាន ឬតាមហាងអាហារជាដើម។ វប្បធម៌នៃការទស្សនាកម្មវិធីទូរទស្សន៍ជាក្រុម ត្រូវបានបាត់បង់បន្តិចម្តងៗក្រោមវត្តមាននៃការរីកចម្រើនលើវិស័យបច្ចេកវិទ្យា និងការនិយមប្រើប្រាស់ទូរសព្ទដៃស្មាតហ្វូនភ្ជាប់អ៊ីនធឺណិត។ ដោយសារកំណើនអ្នកប្រើប្រាស់បណ្តាញសង្គមកើនឡើងច្រើនដូចនេះ គេសង្កេតឃើញមានក្រុមអ្នកបង្កើតវីដេអូខ្លីៗដូចជា៖ រឿងកំប្លែង ឬអប់រំខ្លីៗ និងកម្មវិធីចម្លែកៗផ្សាយនៅលើបណ្តាញសង្គមដូចជា ហ្វេសប៊ុក និងយូធូបកំពុងកើតមានឡើងយ៉ាងផុសផុលៗ។ បច្ចុប្បន្ន ចំនួនអ្នកទស្សនាកម្មវិធីទាំងនេះក៏ហាក់ដូចជាមានសន្ទុះកើនឡើងច្រើនបន្តិចម្តងៗគួរឱ្យកត់សម្គាល់ផងដែរ៕

ដំណើរកម្សាន្តវិលល្បាចពីទីក្រុងតូក្យូ — រមណីយដ្ឋានព្រិលទឹកកក Fujiten Snow Resort & ភូមិបុរាណ Oshinohakkai

ការជិះស្គីកម្សាន្តលើព្រិលទឹកកកនៅរដូវរងារ គឺពេញនិយមខ្លាំងនៅប្រទេសជប៉ុន។ ក្រៅពីជនជាតិជប៉ុន មានជនបរទេសមកពីបណ្តាប្រទេសដទៃ ជាពិសេស ជនជាតិថៃក៏ចូលចិត្តចំណាយពេលសម្រាកកម្សាន្តនាចុង ឬដើមឆ្នាំរបស់ខ្លួន ដើម្បីធ្វើដំណើរទេសចរទៅប្រទេសជប៉ុនជាងដែរ។ រមណីយដ្ឋាន Fujiten Snow Resort ជាទីសដៅទេសចរណ៍សម្រាប់លេងព្រិលទឹកកកដ៏ពេញនិយមមួយកន្លែងនៅខេត្ត Yamanashi ខាងលិចជាប់នឹងទីក្រុងតូក្យូ។ មានចម្ងាយប្រមាណ ១៤០គីឡូម៉ែត្រ និងចំណាយពេលប្រមាណ២ម៉ោងកន្លះ តាមរយៈឡាន ឬឡានក្រុងពីទីក្រុងតូក្យូ នោះគេនឹងធ្វើដំណើរមកដល់រមណីយដ្ឋាននេះ។ ក្រៅពីនេះ ភ្ញៀវទេសចរក៏និយមឆ្លៀតទៅទស្សនាភូមិបុរាណឈ្មោះថា Oshinohakkai ដែលជាទិសដៅទេសចរណ៍ពេញនិយមមួយនៅក្បែរនោះផងដែរ សម្រាប់ដំណើរកម្សាន្តវិលល្បាចពីទីក្រុងតូក្យូ។

រមណីយដ្ឋានព្រិលទឹកកក Fujiten Snow Resort

ស្ថិតនៅជាប់នឹងជើងភ្នំ Fuji រមណីយដ្ឋាន Fujiten Snow Resort បើកទទួលភ្ញៀវទេសចរទូទៅចូលជិះស្គីកម្សាន្តរាល់រដូវរងារ ចាប់ពីអំឡុងពាក់កណ្តាលខែធ្នូ រហូតដល់ដើមខែមេសា។ ភ្ញៀវទេសចរគ្រប់វ័យអាចជិះស្គីលេងកម្សាន្តដោយសេរី ដោយគ្រាន់តែបង់ប្រាក់ថ្លៃចូលកម្សាន្តសម្រាប់ទីលានស្គីដែលខ្លួនចង់ទៅតម្លៃប្រមាណ ៤,០០០យ៉ែន = ៣០ដុល្លារ/ម្នាក់ និងថ្លៃជួលសម្ភារៈសម្រាប់លេងស្គីដូចជា សម្លៀកបំពាក់ជិះស្គី វែនតាការពារព្រិល មួក ស្រោមដៃ និង ជើងស្គី ឬក្តារអិលលើព្រិលទឹកកកជាដើម (តម្លៃជួលសម្ភារៈលេងស្គីឈុតប្រមាណ ៨,៥០០យ៉ែន= ៦៥ដុល្លារ/ម្នាក់) ដែលមានជួលនៅរមណីយដ្ឋានផ្ទាល់។ សម្រាប់កុមារវិញក៏អាចកម្សាន្តនៅទីនោះបានដែរ។ គ្រាន់តែបង់ប្រាក់ថ្លៃចូលក្នុងម្នាក់ ៨០០យ៉ែន អាណាព្យាបាលអាចនាំកូនៗរបស់ខ្លួនចូលជិះក្តារអិលសម្រាប់កុមារ (ថ្លៃជួល៥០០យ៉ែន/មួយ) នៅទីលានមានជម្រាលទាប។

▲ទីលានលេងស្គីសម្រាប់កុមារ

▲ទិដ្ឋភាពរមណីយដ្ឋាន Fujiten Snow Resort

ជាមួយនឹងទិដ្ឋភាពភ្នំ Fuji ឈរលេចត្រដែតយ៉ាងស្តឹមស្កែស្តិតនៅពីក្រោយរមណីយដ្ឋាននេះផង នឹងធ្វើឱ្យភ្ញៀវទេសចរបន្សល់ទុកនូវអនុស្សាវរីយ៍រដូវរងារល្អបំផុតសម្រាប់ខ្លួន រួមទាំងមិត្តភក្តិ និងក្រុមគ្រួសារ។ ភ្នំ Fuji មានកំពស់ ៣,៧៧៦ម៉ែត្រ និងត្រូវបានប្រជាជនជប៉ុនស្គាល់ជាទូទៅថាជាភ្នំនៃសេចក្តីអមតៈ ហើយមានទិដ្ឋភាពស្អាតបំផុតនៅរដូវរងារ ខណៈភ្នំនេះស្រោបទៅដោយព្រិលទឹកកកនៅផ្នែកកំពូល។ មានភ្ញៀវទេសចរជាច្រើនមកកម្សាន្តនៅប្រទេសជប៉ុន ដើម្បីទស្សនា និងថ្ពិតយករូបភាពភ្នំ Fuji នៅរដូវរងារ។ រមណីយដ្ឋាន Fujiten Snow Resort ស្ថិតនៅក្នុងទីតាំងល្អបំផុតមួយសម្រាប់កម្សាន្តលើព្រិលទឹកកក និងគយគន់ភ្នំ Fuji ។

នៅក្នុងរមណីយដ្ឋាន Fujiten Snow Resort ក៏មានអាហារដ្ឋានស្ថិតនៅជាន់ទី១ មានទំហំធំទូលាយផងដែរ។ ជាទូទៅ មានភ្ញៀវទេសចរយ៉ាងច្រើនកុះករមកទទួលទានអាហារថ្ងៃត្រង់ ការហ្វេក្តៅ ឬភេសជ្ជៈនានា រួមទាំងអាហារសម្រន់ក្នុងអំឡុងពេលសម្រាកពីការជិះស្គីកម្សាន្តនៅក្នុងអាហារដ្ឋាននេះ។

ភូមិបុរាណ Oshinohakkai

មានចម្ងាយប្រមាណ ១៧គីឡូម៉ែត្រ និងចំណាយពេលប្រមាណ ៣០ នាទីតាមយានយន្តពីរមណីយដ្ឋាន Fujiten Snow Resort ភ្ញៀវទេសចរអាចធ្វើដំណើរទៅទស្សនា Oshinohakkai ដែលជាទិសដៅទេសចរណ៍ពេញនិយមសម្រាប់គយគន់ទេសភាពភ្នំ Fuji ពីកូនភូមិបុរាណតូចមួយក្បែរជើងភ្នំ Fuji ។ នៅទីនេះមានថ្លុកទឹកធម្មជាតិថ្លាយង់ហូរផុសចេញពីភ្នំ Fuji ។ ថ្លុកទឹកកណ្តាលមានជម្រៅដល់ទៅ ៨ម៉ែត្រ ត្រូវបានអ្នកស្រុកជឿថាជាទីស័ក្តិសិទ្ធ សម្រាប់ព្យាបាលរោគាផ្សេងៗ។

ក្រៅពីទស្សនាថ្លុកទឹកធម្មជាតិ និងថតរូបអនុស្សាវរីយ៍ជាមួយភ្នំ Fuji ភ្ញៀវទេសចរអាចជាវចំណីអាហារប្រពៃណីជប៉ុនដែលផលិតដោយប្រជាជនរស់នៅក្នុងស្រុកជាវត្ថុអនុស្សាវរីយ៍សម្រាប់មិត្តភក្តិ និងសាច់ញាតិក្នុងដំណើរកម្សាន្តរដូវរងារទៅកាន់ខេត្ត Yamanashi ដែលមានភ្នំ Fuji ដ៏ល្បីល្បាញ៕

▲ថ្លុកទឹកកណ្តាលជម្រៅប្រមាណ៨ម៉ែត្រដែលគេជឿថាជាទីស័ក្តិសិទ្ធ

▲ ទឹកស័ក្តិសិទ្ធ(ក្បែរថ្លុកកណ្តាល)ដែលគេជឿថាញ៉ាំព្យាបាលរោគ

◀មានភ្ញៀវទេសចរជាច្រើនចូលទិញវត្ថុអនុស្សាវរីយ៍នៅហាងលក់ចំណីអាហារជប៉ុនវេចខ្ចប់យ៉ាងស្អាតជាច្រើនមុខនៅក្បែរខាងចំណុចទស្សនា

▲ សណ្តែកសៀងកិនជប៉ុន(សម្រាប់ធ្វើជាស៊ុប)

▼រូបថតអនុស្សាវរីយ៍របស់និស្សិតខ្មែរនៅភូមិបុរាណ Oshinohakkai

▲ វ៉ាសាប៊ីក៏ភ្ញៀវទេសចរនិយមជៀវផងដែរ

"ជនជាតិជប៉ុនមានវប្បធម៌ការងារល្អៗជាច្រើន ដែលខ្មែរយើងគួរស្វែងយល់ និងរៀនសូត្រ"

បងប្រុស ណុល នឿន (៣៧ឆ្នាំ) ជាអ្នកគ្រប់គ្រងនៅក្រុមហ៊ុនផលិតនំអង្គរឃុកយី ដែលមានហាងកាហ្វេ និងហាងលក់វត្ថុអនុស្សាវរីយ៍ជប៉ុនដ៏មានប្រជាប្រិយភាពមួយក្នុងក្រុងសៀមរាប។ តាមរយៈការងារជាអ្នកគ្រប់គ្រងរយៈពេលជាង ១០ឆ្នាំកន្លងទៅ បងប្រុស នឿន បានចែករំលែកការយល់ឃើញពីបទពិសោធន៍ការងារនៅក្រុមហ៊ុនជប៉ុន និងក្នុងអំឡុងពេលបងប្រុសទៅទស្សនកិច្ចនៅប្រទេសជប៉ុនកាលពីខែតុលា ឆ្នាំ២០១៩ កន្លងទៅ ជូនទស្សនាវដ្តីញញឹមខ្មែរដូចតទៅ។

ឆ្លើយតបនឹងសំណួរដែលបុគ្គលិកទស្សនាវដ្តីញញឹមខ្មែរបានសាកសួរអំពីការយល់ឃើញរបស់បងប្រុស ចំពោះដំណើរទស្សនកិច្ចទៅកាន់ប្រទេសជប៉ុនរយៈពេលជិត ២សប្តាហ៍ កាលពីជាង៣ឆ្នាំមុន បងប្រុស នឿន បានរៀបរាប់ដោយរួសរាយរាក់ទាក់មិនដាច់ពីមាត់អំពីចំណុចល្អចំពោះស្មារតីការងាររបស់ជនជាតិជប៉ុន ដែលខ្លួនបានមើលឃើញផ្ទាល់ភ្នែកនៅប្រទេសជប៉ុន។ បងប្រុស នឿន៖ «នៅពេលទៅដល់ប្រទេសជប៉ុន ខ្ញុំសង្កេតឃើញថាការរស់នៅរបស់ជនជាតិជប៉ុន គឺធ្វើអ្វីមានរបៀបយកចិត្តទុកដាក់ និងហ្មត់ចត់ ជាពិសេសនោះ ជនជាតិជប៉ុនធ្វើការងារហ័ស ហើយគេរត់ហូតដើម្បីធ្វើការងារគេឱ្យទាន់សភាពការណ៍»។ បន្ទាប់ពីថ្លែងដូច្នោះហើយ បងប្រុស នឿន ក៏បានបង្ហើបប្រាប់ពីចំណុចអវិជ្ជមានបន្តិចអំពីរបៀបធ្វើការងាររបស់ក្រុមការងារគាត់ដោយលើកឡើងដូច្នេះថា៖ «ជនជាតិជប៉ុន ពេលគេធ្វើកិច្ចការអ្វីមួយគឺធ្វើដោយយកចិត្តទុកដាក់និងផ្តោតទៅលើការងារនោះរហូតចប់សព្វគ្រប់អស់ទើបគេចាប់ផ្តើមធ្វើការងារមួយទៀត ដែលខុសពីខ្មែរយើងភាគច្រើនមិនសូវយកចិត្តទុកដាក់នឹងការងារទេ ហើយចូលចិត្តធ្វើការងារដោយចាប់នេះបន្តិចចាប់នោះបន្តិច»។ ជាមួយគ្នានេះ បងប្រុស នឿន បានបន្តរៀបរាប់ពីចំណុចល្អដែលខ្លួនបានឃើញនៅជប៉ុនទៀតដូច្នេះ៖ «នៅជប៉ុន ប្រជាជនគេឈរតម្រង់ជួររង់ចាំទិញអ្វីមួយយ៉ាងមានរបៀប។ ហើយចំណុចពិសេសមួយទៀតនោះគឺថា ជនជាតិជប៉ុនចូលចិត្តធ្វើខ្លួនឱ្យរវល់ច្រើន និងមិនសូវមានពេលទំនេរទេ ហើយជនជាតិនេះចូលចិត្តច្នៃប្រឌិត និងបង្កើតថ្មីណាស់។ ជាក់ស្តែង ខ្ញុំឃើញគេចេះច្នៃស្លឹកត្រែយកទៅបង្កើតជាភេសជ្ជៈសម្រាប់លក់រកកម្រៃបានទៀតផង។ ការវេចខ្ចប់អីវ៉ាន់នៅតាមហាងលក់នីមួយៗ គឺពិតជាមានជំនាញច្បាស់លាស់ និងមានសោភ័ណ្ឌល្អណាស់!»

គួរបញ្ជាក់ដែរថា បងប្រុស នឿង បានទៅទស្សនាប្រទេសជប៉ុន ក្នុងគោលបំណងធ្វើកម្មសិក្សានៅរោងចក្រផលិតនំជប៉ុន តាមការអញ្ជើញរបស់ប្រធានក្រុមហ៊ុននំអង្គរឃុកយី ដែលគាត់បម្រើការនៅក្នុងក្រុងសៀមរាបបច្ចុប្បន្ន។ ក្រោយពីបានឃើញផ្ទាល់ភ្នែកនូវបច្ចេកវិទ្យាទាន់សម័យ និងមានស្តង់ដារអនាម័យខ្ពស់នៅតាមបណ្តាក្រុមហ៊ុនផលិតនោះ បងប្រុសក៏បានស្ងើចសរសើរខ្លាំងពីចង្វាក់ផលិតកម្មជប៉ុនដែរ។ បងប្រុស នឿន៖ «នៅពេលខ្ញុំចូលទៅដល់រោងចក្រធ្វើនំ និងសូកូឡា នៅទីក្រុងអូសាកា និង តូក្យូ ដើម្បីមើលពីសកម្មភាពផលិត ឃើញថាស្ទើរគ្រប់យ៉ាងដំណើរការដោយម៉ាស៊ីនទំនើប គឺថាការផលិតពីមួយជំហានទៅមួយជំហាន ធ្វើឡើងដោយម៉ាស៊ីនទាំងអស់ ហើយមានបុគ្គលិកតិចតួចសម្រាប់តែជួយសម្រួលកន្លែងខ្លះៗប៉ុណ្ណោះ»។

▲ បុគ្គលិកហាងនំអង្គរឃុកយី

ហាងនំអង្គរឃុកយី ត្រូវបានបង្កើតឡើងនៅឆ្នាំ២០០៤ ក្នុងគោលបំណងបង្កើតការងារសម្រាប់នារីខ្មែរស្រុកនៅខេត្តសៀមរាប និងដើម្បីបង្ហាញដល់ភ្ញៀវទេសចរជប៉ុនថា ប្រជាជនខ្មែរអាចផលិតនំមានរសជាតិឈ្ងុយឆ្ងាញ់ និងមានអនាម័យ ដោយប្រើប្រាស់វត្ថុធាតុដើមក្នុងស្រុករបស់ខ្លួន។ មុនមានវិបត្តិជំងឺកូវីដ១៩ ផ្ទុះឡើង ក្រុមហ៊ុនផលិតនំអង្គរឃុកយី មានបុគ្គលិកប្រមាណ៩០នាក់ ហើយក្នុងនោះ ៩០ភាគរយគឺជាស្ត្រី។ ដោយសារជាក្រុមហ៊ុនផលិតនំ រួមទាំងមុខម្ហូបនៅក្នុងហាងកាហ្វេផងតម្រូវតាមស្តង់ដារជប៉ុន បងប្រុស នឿន ត្រូវទទួលរ៉ាប់រងនូវទំនួលខុសត្រូវច្រើនលើការបណ្តុះបណ្តាលបុគ្គលិកឱ្យយល់ពីការផលិតមួយដែលមានស្តង់ដារខ្ពស់។ តាមរយៈការមកបណ្តុះបណ្តាលផ្ទាល់ពីក្រុមការងារមកពីប្រទេសជប៉ុនកន្លងមក បានធ្វើឱ្យបុគ្គលិកហាង និងរូបបងប្រុសផ្ទាល់ទទួលបទពិសោធន៍ និងចំណេះដឹងច្រើនពីវគ្គបណ្តុះបណ្តាលទាំងនោះ។

ទោះជាយ៉ាងនេះក្តី បច្ចុប្បន្ន ក្នុងនាមជាអ្នកគ្រប់គ្រង និងទទួលបន្ទុកបណ្តុះបណ្តាលបុគ្គលិកក្នុងក្រុមហ៊ុនផ្ទាល់ បងប្រុស នឿន នៅសង្កេតឃើញពីចំណុចអសកម្មមួយចំនួនរបស់បុគ្គលិកខ្មែរ បើប្រៀបធៀបនឹងបុគ្គលិកជប៉ុន។ បងប្រុសបានបង្ហាញពីការយល់ឃើញចំពោះទម្លាប់ការងាររបស់បុគ្គលិកខ្មែរដូច្នេះ៖ «ខ្ញុំយល់ថាការបំពេញការងាររបស់បុគ្គលិកខ្មែរយើង នៅមានចំណុចខ្វះខាតច្រើន និងមិនសូវសកម្មដូចជប៉ុនទេ ដូចជាការមកយឺតនិងមិនសូវយល់ពីការងារជាក្រុមជាដើម។ ឧទាហរណ៍ នៅពេលទំនេរពួកគាត់ចុចទូរសព្ទឬធ្វើអ្វីផ្សេងៗទៀតដែលពុំទាក់ទងនឹងការងារដូចនេះក្នុងនាមខ្ញុំជាអ្នកគ្រប់គ្រងពួកគាត់ ខ្ញុំត្រូវខិតខំរកការងារដើម្បីដាក់ឱ្យបុគ្គលិកធ្វើតាមជំនាញក្នុងផ្នែករបស់ពួកគាត់។ ខុសពីជនជាតិជប៉ុន គឺបុគ្គលិកម្នាក់ៗមានទំនួលខុសត្រូវចំពោះការងារ និងមិនទុកឱ្យខ្លួនទំនេរច្រើននៅកន្លែងការងារនោះឡើយ គឺគេតែងតែរកការងារធ្វើដោយខ្លួនឯងក្នុងពេលការងារ»។ បងប្រុសបានបន្ថែមទៀតថា៖ «កន្លងមកមានជនជាតិជប៉ុនមកហាត់ការជាអ្នកគ្រប់គ្រងបណ្តោះអាសន្នក្នុងហាងយើងពីមុនដែរ ហើយពួកគាត់ភាគច្រើន ក្រោយពីបញ្ចប់ការងារពីទីនេះ គាត់បានលើកឡើងពីផលលំបាកក្នុងការស្វែងរកការងារឱ្យបុគ្គលិកខ្មែរយើងធ្វើ ដោយសារភាពថាពួកគាត់ខ្វះសមត្ថភាពត្រង់ចំណុចនេះ»។ បងប្រុសបានសម្តែងនូវការយល់ឃើញស្រដៀងនឹងជនជាតិជប៉ុន ដែលបានលើកឡើងនូវបញ្ហាពិបាករកការងារឱ្យបុគ្គលិកធ្វើ ខណៈបងប្រុសសង្កេតឃើញថាមានបុគ្គលិកខ្មែរច្រើនពុំសូវយល់ និងបំពេញការងារឱ្យសកម្មក្នុងជំនាញរបស់ខ្លួនចេញពីខ្លួនគាត់ផ្ទាល់។

◀ រូបចុះធ្វើកម្មសិក្សាផ្ទាល់នៅហាងផលិតការ៉ែម ក្នុងក្រុងអូសាកា (តុលា ឆ្នាំ២០១៩)

យ៉ាងណាមិញ បងប្រុស នឿន ក៏បានលើកសរសើរពីចំណុចល្អជាច្រើនរបស់ក្រុមហ៊ុនខ្លួន ដោយសារវាបានបង្កើតការងារ និងទំនុកបម្រុងច្រើនដល់ស្ត្រីខ្មែរស្រុកនៅក្នុងខេត្តសៀមរាបដែរ។ បងប្រុស នឿន ៖ «តាមពិតទៅក្រុមហ៊ុនយើងនេះ គឺផ្តល់ឱកាសការងារច្រើនទៅដល់ស្ត្រីខ្មែរ ដែលនេះជាគំនិតរបស់ស្ថាបនិកក្រុមហ៊ុនដំបូងគឺ លោកស្រី សាជីកុ ជាជនជាតិជប៉ុន ដោយលោកស្រីយល់ថា ស្ត្រីខ្មែរភាគច្រើននៅពេលដែលពួកគាត់រៀបការមានគ្រួសារហើយ មានស្ត្រីខ្មែរមួយចំនួនជួបបញ្ហាប្រឈមជាមួយប្តីដូចជាការឈ្លោះប្រកែកគ្នា ឬជួបអំពើហិង្សា ដោយសារតែពេលរៀបការរួច ស្ត្រីបាត់បង់ចំណូល ឬឱកាសការងារ ព្រោះពួកគាត់ត្រូវនៅផ្ទះមើលថែកូន ពោលគឺគ្មានចំណូលសម្រាប់គ្រួសារ។ ព្រោះមូលហេតុនេះហើយ ទើបលោកស្រី សាជីកុ ចង់ផ្តល់ឱកាសឱ្យស្ត្រីខ្មែរមានការងារធ្វើ ដើម្បីមានចំណូលជួយដល់ក្រុមគ្រួសារ ហើយលើសពីនេះទៅទៀត ក្រុមហ៊ុនយើងតែងតែព្យាយាមជួយសម្រួលភាពលំបាកផ្សេងៗដល់បុគ្គលិកខ្លួនដូចជា ការអនុវត្តិច្បាប់ក្រោយពេលសម្រាលកូនត្រឹមត្រូវ និងការអនុញ្ញាតឱ្យកកូនមកកន្លែងធ្វើការ និងមានបន្ទប់សម្រាប់មើលថែទាំកុមារ និងឱ្យកូនតូចៗរបស់បុគ្គលិកសម្រាកក្នុងអំឡុងពេលម្តាយគាត់បំពេញការងារនៅក្នុងហាងរបស់យើងជាដើម»។

▶ រូបថតអនុស្សាវរីយ៍ជាមួយម្ចាស់ហាងលក់តែបៃតងនៅទីក្រុងតូក្យូ (តុលា ឆ្នាំ២០១៩)

ហាងនំអង្គរឃុកយី៖

Add: On the main road to Angkor Wat, in front of Sofitel Hotel, Siem Reap, CAMBODIA
TEL: (855)-(0)63-964-770
Fax: (855)-(0)63-965-975

ហោរាសាស្ត្រប្រចាំខែ

ម្សាញ់

រាសីឡើងខ្ពស់ត្រដែត។ **ការកសុ៊ះ** ឆ្នាំថ្មីគំនិតថ្មី។ អាចបណ្តាក់ទុនតាមទីជិតឆ្ងាយ មិនជាផ្លូវគោក ឬផ្លូវទឹកឡើយ គឺសមប្រកបតែទាំងអស់ ព្រោះអាចរកផលចំណេញយ៉ាងគាប់ចិត្តត្រឡប់ចូលផ្ទះវិញ។ **ការងារៈ** ពិតមែនតែការងារទទួលបានជោគជ័យគ្រប់ការកិច្ចក្តី តែអ្វីដែលត្រូវចៀសវាងនោះគឺមិនត្រូវប្រគល់កិច្ចការសំខាន់ឱ្យគេកាន់កាប់ជំនួសឡើយ។ **សេដ្ឋកិច្ចៈ** ពិតមែនតែចំណូលច្រើនពីគ្រប់ទិសទីក្តី តែប្រយ័ត្នទ្រព្យច្រើន ទុក្ខច្រើន អាចជួបគ្រោះចោរលួចឆក្លន់។ **សុខភាពៈ** សុខភាពពុំមានបញ្ហាចោទឡើយ។ **ស្នេហាៈ** ចំពោះអ្នកនៅលីវដែលពុំទាន់មានគូគាប់ គឺជាឱកាសល្អក្នុងការស្វែងរក។ **គ្រោះថ្នាក់ៈ** ពុំមានចូបគ្រោះថ្នាក់អ្វីធំដុំឡើយ។

រាសីល្អមធ្យម។ **ការកសុ៊ះ** ការរកស៊ីពិតមែនតែស្រុតចុះបន្តិចក្តី តែពុំមានបញ្ហាចោទធ្ងន់ធ្ងរឡើយ ព្រោះនៅតែមានទំនិញទិញចូលលក់ចេញជាហូរហែ។ **ការងារៈ** ទោះបានប្រកបការងារអ្វីក៏ដោយ គោងតែត្រិះរិះពិចារណាឱ្យបានច្បាស់លាស់ ជាពិសេសមុននឹងរួមការងារជាមួយនឹងនរណាម្នាក់ ទើបមិននាំអំពល់ទុក្ខដាក់ខ្លួន។ **សេដ្ឋកិច្ចៈ** ពិតមែនតែមានចំណូលច្រើនគួរសមក្តី តែអ្វីដែលត្រូវចៀសវាងនោះគឺមិនត្រូវឱ្យគេជំពាក់បំណុលឡើយ។ **សុខភាពៈ** ត្រូវយកចិត្តទុកដាក់ចំពោះអនាម័យនៃចំណីអាហារ។ **ស្នេហាៈ** ចំពោះគូស្នេហ៍មានភាពស្និទស្នាលដូចប្រក្រតី។ **គ្រោះថ្នាក់ៈ** ប្រយ័ត្នគ្រោះថ្នាក់រលាកទឹកក្តៅ។

រាសីស្រុតចុះ។ **ការកសុ៊ះ** ការរកស៊ីជួបរឿងរកាំរកូសច្រើន ដូច្នេះត្រូវចេះអត់ធ្មត់ និងម្ចាប់ចិត្តឱ្យបានត្រជាក់ ទើបអ្វីៗអាចដំណើរការបានស្រួល។ **ការងារៈ** អ្វីដែលត្រូវចៀសវាងនោះ គឺមិនត្រូវយកខ្លួនទៅធានារឿងរបស់អ្នកដទៃឡើយ។ **សេដ្ឋកិច្ចៈ** នៅដើមខែពិតមែនតែមានចំណូលខ្សត់ខ្សោយ តែចាប់ពីពាក់កណ្តាលខែនឹងមានចំណូលហូរចូលច្រើនគួរសម។ **សុខភាពៈ** ត្រូវយកចិត្តទុកដាក់ឱ្យបានទៀតទាត់ពេលវេលា។ **ស្នេហាៈ** ចំពោះគូស្នេហ៍ប្រយ័ត្នមានជនទី៣ចូលជ្រៀតជ្រែក។ **គ្រោះថ្នាក់ៈ** គ្រោះថ្នាក់ចរាចរណ៍នឹងកើតមានឡើងក្នុងការបើក-បរខ្វះការប្រុងប្រយ័ត្ន។

រាសីល្អមធ្យម។ **ការកសុ៊ះ** ការរកស៊ីពិតមែនតែមានភាពល្អប្រសើរជាបណ្តើរៗក្តី តែអ្វីៗមិនទាន់ដំណើរការបានស្រួលឡើយ។ ដូច្នេះមិនត្រូវបណ្តាក់ទុនធំពេកទេ។ **ការងារៈ** ក្នុងខែនេះ ពិតមែនតែរាល់សម្ពាធការងារបានសាបរលាបជាបណ្តើរៗក្តី។ តែទោះបានប្រកបការងារអ្វីៗតោងមានស្មារតីប្រុងប្រយ័ត្នជានិច្ច។ **សេដ្ឋកិច្ចៈ** ពិតមែនតែមានចំណូលច្រើនគួរសមក្តី តែពុំមានសល់អ្វីជាដុំកំភួនោះឡើយ ព្រោះខ្ជង់ចំណូលចំណាយប្រហាក់ប្រហែលគ្នា។ **សុខភាពៈ** ត្រូវចៀសវាងការល្មោភស៊ីល្មោភផឹក ទើបមិនអន្តរាយដល់ក្រពះពោះវៀន។ **ស្នេហាៈ** ចំពោះគូស្នេហ៍ប្រយ័ត្នមានអ្នកក្រៅនាំរឿងមកអុជអាល។ **គ្រោះថ្នាក់ៈ** ប្រយ័ត្នគ្រោះថ្នាក់លង់ទឹក។

រាសីឡើងខ្ពស់ត្រដែត។ **ការកសុ៊ះ** ការរកស៊ីច្រើនមានប្រៀបជាងគេ ដូច្នេះត្រូវរៀសរៀញាប់ដៃញាប់ជើងបន្តិច ព្រោះឱកាសល្អកម្រមាន ពុំមានច្រើនទៀតឡើយ។ **ការងារៈ** ទោះបានប្រកបការងារអ្វីក៏ដោយ ក៏អាចសម្រេចផលដូចបំណងប្រាថ្នាទាំងអស់ ជាពិសេសបើមានទុក្ខធុរៈត្រូវពឹកពាក់នរណាម្នាក់ក៏ជោគជ័យដែរ។ **សេដ្ឋកិច្ចៈ** ពិតមែនតែមានចំណូលពីគ្រប់ទិសទីក្តី តែចំពោះទ្រព្យក្តៅក្រហាយក៏គប្បីកុំលូកដៃទទួលយកឱ្យសោះ។ **សុខភាពៈ** សុខភាពពុំមានបញ្ហាចោទឡើយ។ **ស្នេហាៈ** ចំពោះគូស្នេហ៍មានភាពល្មួកល្មើនល្មមណាស់។ **គ្រោះថ្នាក់ៈ** ពុំមានជួបគ្រោះថ្នាក់ធ្ងន់ដុំគួរឱ្យកត់សម្គាល់ឡើយ។

រាសីស្រុតចុះ។ **ការកសុ៊ះ** បើមានមនុស្សចម្លែកយករបស់របរមកបញ្ចាំ ឬលក់ក្នុងតម្លៃធូរថ្លៃយ៉ាងណាក្តី កុំទទួល ឬទិញយកឱ្យសោះ ទើបមិននាំទុក្ខដាក់ខ្លួន។ **ការងារៈ** មិនត្រូវរួមការងារជាមួយមនុស្សដែលមានសម្តីផ្អែម និងមានអំនួតក្អែងក្អាងឡើយ ទើបមិនចាញ់បោកគេ។ **សេដ្ឋកិច្ចៈ** ពិតមែនតែចំណូលខ្សត់ខ្សោយ តែបើចេះចាយវាយដោយក្បិតក្បៀតគឺពុំមានចោទដល់សេដ្ឋកិច្ចគ្រួសារឡើយ។ **សុខភាពៈ** ត្រូវឆ្លៀតពេលហាត់ប្រាណឱ្យបានច្រើន។ **ស្នេហាៈ** ចំពោះគូស្នេហ៍ជួបរឿងរកាំរកូសច្រើន។ **គ្រោះថ្នាក់ៈ** ប្រយ័ត្នគ្រោះថ្នាក់ធ្លាក់ពីលើទីខ្ពស់។

រាសីឡើងខ្ពស់ត្រដែត។ **ការកសុ៊ះ** បើមានបងប្អូនញាតិមិត្តស្គាត់មកបបួលរកស៊ីចូលហ៊ុនជាមួយ កុំឧកឧានឱ្យសោះ ព្រោះជាដៃគូរកស៊ីដែលមានចិត្តត្រង់ទៅត្រង់មក។ **ការងារៈ** ចំពោះបុគ្គលិកកម្មករដែលបម្រើការនៅតាមបណ្តាក្រុមហ៊ុន ឬរោងចក្រនានា នឹងទទួលបានការកោតសរសើរ និងតួនាទីការងារយ៉ាងគាប់ចិត្ត។ **សេដ្ឋកិច្ចៈ** មានចំណូលច្រើនពីគ្រប់ទិសទី។ អាចបង្កើតដើមទុនរកស៊ី និងបើកហាងលក់ដូរថ្មីបាន។ **សុខភាពៈ** នៅដើមខែមានសុខភាពល្អ តែនៅចុងខែមានជំងឺឈឺថ្កាត់ច្រើន។ **ស្នេហាៈ** ចំពោះកំលោះក្រមុំអាចសាងពន្លកស្នេហាបានយ៉ាងផ្អែមល្ហែម។ **គ្រោះថ្នាក់ៈ** គ្រោះថ្នាក់ពុំមានអ្វីធំដុំគួរឱ្យកត់សម្គាល់ឡើយ។

រាសីស្រុតចុះ។ **ការកសុ៊ះ** ការរកស៊ីដែលសង្ឃឹមថាអាចរកប្រាក់ចំណេញយ៉ាងងាយសោះ បែរជាខកខានទៅវិញ ព្រោះផលចំណេញបានបោលហួសធ្លាក់ដល់ដៃអ្នកដទៃទៅវិញ។ **ការងារៈ** មិនត្រូវធ្វើកិច្ចការងារអ្វីដែលល្មើសនឹងច្បាប់ឡើយ ពុំនោះទេអាចមានទុក្ខទោសជាពុំខាន។ **សេដ្ឋកិច្ចៈ** ចំណូលខ្សត់ខ្សោយ និងរកបានដោយកម្លាំងញើសឈាមទៀតផង។ **សុខភាពៈ** ត្រូវឆ្លៀតពេលសម្រាក និងហាត់ប្រាណ ឬលេងកីឡាឱ្យបានច្រើន។ **ស្នេហាៈ** ចំពោះគូស្នេហ៍ជួបរឿងរកាំរកូសច្រើន។ **គ្រោះថ្នាក់ៈ** គ្រោះថ្នាក់អាចកើតមានឡើងក្នុងការបើកបរពេលយប់ និងក្រោយពេលស្រវឹងជោគជាំ។

រាសីឡើងខ្ពស់ត្រដែត។ **ការកសុ៊ះ** ការរកស៊ីបានកាក់កបល្អណាស់។ មានទំនិញទិញចូលលក់ចេញឥតទំនេរដៃ ហើយបើទោះជាបានជួបគូប្រជែងក៏មិនភ័យព្រួយដែរ។ **ការងារៈ** រាល់ឧបសគ្គ និងរាល់រឿងចង្រៃឧបទ្រពបានសាបរលាបបាត់ស្រមោលរលីង។ ដូច្នេះអាចប្រកបការងារបានពេញដៃពេញជើង ធ្វើច្រើនបានច្រើន។ **សេដ្ឋកិច្ចៈ** ពិតមែនតែមានចំណូលច្រើនមកពីគ្រប់ទិសទីក្តី តែចំពោះអ្នករកស៊ីហ៊ុនគួរតែធ្វើបញ្ជីលុយកាក់ឱ្យបានច្បាស់លាស់ ទើបពុំមានវិវាទកើតឡើង។ **សុខភាពៈ** នៅចុងខែអាចមានជំងឺឈឺធ្មេញមករំខានខ្លះៗ។ **ស្នេហាៈ** ចំពោះគូស្នេហ៍ប្រកបដោយភាពផ្អែមត្រជាក់ដូចទឹកឃ្មុំ។ **គ្រោះថ្នាក់ៈ** ពុំមានគ្រោះថ្នាក់អ្វីធំដុំគួរឱ្យកត់សម្គាល់ឡើយ។

រាសីល្អមធ្យម។ **ការកសុ៊ះ** ការរកស៊ីពិតមែនតែធ្លាក់ចុះបន្តិចក្តី។ តែពុំមានបញ្ហាអ្វីចោទធ្ងន់ធ្ងរឡើយ ព្រោះនៅតែមានអតិថិជនជួយគាំទ្រជាហូរហែ។ **ការងារៈ** មុនប្រគល់ ឬទទួលទំនិញគ្រប់ទស្ងសារពើត្រូវពិនិត្យមើលគុណភាព និងរាប់ចំនួនឱ្យត្រឹមត្រូវទើបពុំមានរឿងឈ្លោះប្រកែកគ្នា។ **សេដ្ឋកិច្ចៈ** ពិតមែនតែចំណូលច្រើនគួរសមក្តី តែពុំមានសល់អ្វីជាដុំកំភួនឡើយ ព្រោះរកបានច្រើនចាយច្រើនមិនខុសពីទុកធំក្តោងធំនោះដែរ។ **សុខភាពៈ** ចំពោះសុខភាពត្រូវយកចិត្តទុកដាក់ចំពោះអនាម័យនៃចំណីអាហារ។ **ស្នេហាៈ** ចំពោះគូស្នេហ៍ប្រយ័ត្នអ្នកក្រៅនាំរឿងអុចអាល។ **គ្រោះថ្នាក់ៈ** ប្រយ័ត្នគ្រោះថ្នាក់ឆក់ខ្សែភ្លើង។

រាសីល្អមធ្យម។ **ការកសុ៊ះ** ការរកស៊ីមានភាពល្អប្រសើរជាបណ្តើរៗក្តី។ តែនៅមានឧបសគ្គខ្លះៗដែរ ដូច្នេះការរកស៊ីឱ្យចេះសម្របសម្រួលទៅតាមកាលៈទេសៈប្រែប្រួល។ **ការងារៈ** បើមានមនុស្សសម្តីផ្អែមត្រជាក់ជាធ្មាក់ទាក់ទងលោកអ្នករួមការងារ គោងតែប្រយ័ត្នប្រយែងក្រែងចាញ់បោកគេនាំអំពល់ទុក្ខដាក់ខ្លួន។ **សេដ្ឋកិច្ចៈ** ពិតមែនតែមានចំណូលច្រើនគួរសមក្តី តែពុំមានសល់អ្វីជាដុំកំភួនឡើយ ព្រោះចាយវាយខ្លះខ្លាយពេក។ **សុខភាពៈ** ត្រូវចៀរវាងល្មោភស៊ីល្មោភផឹក។ **ស្នេហាៈ** ចំពោះគូស្នេហ៍មានទាស់តែចេះអត់ឱនឱ្យគ្នាទៅញែទៅមកទើបបានសុខក្បាលសប្បាយចិត្ត។ **គ្រោះថ្នាក់ៈ** ប្រយ័ត្នគ្រោះថ្នាក់មុតកាំបិតពូថៅ និងឧបការណ៍មុតស្រួច។

រាសីស្រុតចុះ។ **ការកសុ៊ះ** មិនត្រូវហានប្រថុយប្រថានក្នុងការបណ្តាក់ទុនរកស៊ីដោយទ្រុងទ្រាយធំពេកទេ ហើយក៏មិនត្រូវប្រកបរបរផ្តែកល្បែងស៊ីសងដែរ។ **ការងារៈ** បានក្របកការងារអ្វីក៏ដោយ គឺត្រូវធ្វើដោយខ្លួនឯងផ្ទាល់ ព្រោះហ៊ានតែពឹកពាក់គេធ្វើជំនួស គឺគេកិបកេងយកផលចំណេញអស់។ **សេដ្ឋកិច្ចៈ** ក្នុងខែនេះ ចំណូលខ្សត់ខ្សោយ។ ដូច្នេះត្រូវកាត់បន្ថយការចាយវាយដោយក្បិតក្បៀតបន្តិចទើបនៅចុងខែមិនខ្វះមុខខ្វះក្រោយ។ **សុខភាពៈ** ត្រូវហូបចុកឱ្យបានទៀងពេលវេលា និងហាត់ប្រាណ ឬលេងកីឡាឱ្យបានច្រើន។ **ស្នេហាៈ** ចំពោះចំណងស្នេហ៍ រវាងគូស្នេហ៍អាររង្គោះរង្គើរ ដោយមានជនទី៣ចូលជ្រៀតជ្រែក។ **គ្រោះថ្នាក់ៈ** ប្រយ័ត្នគ្រោះថ្នាក់ដួលថ្លោះជើង។



មករា-កុម្ភៈ ២០២៣

រាសីឡើងខ្ពស់ត្រដែត។ **ការរកស៊ីៈ** នៅតែកាក់កបដដែល។ មានទំនិញលក់ចេញទិញចូលឥតទំនេរដៃហើយថ្វីបើមានអតិថិជនខ្វះបំណុលខ្លះៗសង់មិនគ្រប់ក្តីក៏មិនភ័យញ្ញួយមានការបាត់បង់១កាក់១សេនដែរ។ **ការងារៈ** ទោះបានប្រកបការងារអ្វីក៏ដោយក៏អាចទទួលបានផលសម្រេចតាមបំណងប្រាថ្នាទាំងអស់ជាពិសេសចំពោះអ្នកដែលកំពុងតែស្វែងរកការងារធ្វើក៏អាចសម្រេចដូចបំណងប្រាថ្នាដែរ។ **សេដ្ឋកិច្ចៈ** ពិតមែនតែមានចំណូលច្រើនពីគ្រប់ទិសទីក្តី តែទ្រព្យច្រើនទុក្ខច្រើន។ ប្រយ័ត្នជួបគ្រោះចោរលួចឆក់ប្លន់។ **សុខភាពៈ** នៅចុងខែអាចមានជំងឺឈឺថ្កាត់ច្រើនមកញាំញី។ **ស្នេហាៈ** ចំពោះគូស្នេហ៍មានភាពល្អូកល្អិនល្អណាស់។ **គ្រោះថ្នាក់ៈ** ពុំមានជួបគ្រោះថ្នាក់អ្វីធំដុំគួរឱ្យកត់សម្គាល់ឡើយ។

រាសីស្រុតចុះ។ **ការរកស៊ីៈ** ការរកស៊ីច្រើនចាញ់ប្រៀបគេ ដោយការបង្វិលដើមទុនមានភាពយឺតយ៉ាវ និងជួបឧបសគ្គច្រើនទៀតផង។ **ការងារៈ** ទោះបានប្រកបការងារអ្វីក៏ដោយ តោងប្រយ័ត្នប្រយែងក្រែងធ្លាក់ចូលក្នុងល្បិចកលគេនាំឱ្យមានទុក្ខដាក់ខ្លួន។ **សេដ្ឋកិច្ចៈ** ពិតមែនតែមានចំណូលខ្លះៗក្តី តែពុំមានសល់អ្វីឡើយ ព្រោះខ្ទង់ចំណាយធំជាងខ្ទង់ចំណូល។ **សុខភាពៈ** ត្រូវឆ្លៀតពេលសម្រាកឱ្យបានច្រើន និងមិនត្រូវធ្វើការធ្ងន់ធ្ងរហួសកម្លាំងឡើយ។ **ស្នេហាៈ** ចំពោះគូស្នេហ៍ជួបរឿងរកាំរកូសច្រើន។ **គ្រោះថ្នាក់ៈ** ប្រយ័ត្នគ្រោះថ្នាក់ធ្លាក់ពីទីខ្ពស់។

រាសីល្អមធ្យម។ **ការរកស៊ីៈ** ការរកស៊ីមានភាពល្អប្រសើរជាបណ្តើរៗ។ ដូច្នេះត្រូវញាប់ដៃញាប់ជើងបន្តិច ទើបលាភសក្តរៈមិនបោលហួសដល់ដៃអ្នកដទៃឡើយ។ **ការងារៈ** ទោះបានប្រកបការងារអ្វីក៏ដោយ តោងមានស្មារតីប្រុងប្រយ័ត្នជាប់ជានិច្ចជាពិសេសមុនពេលចុះហត្ថលេខា ឬផ្ទិតស្នាមមេដៃត្រូវពិនិត្យពិច័យឱ្យបានម៉ត់ចត់។ **សេដ្ឋកិច្ចៈ** ពិតមែនតែមានចំណូលច្រើនគួរសមក្តី តែពុំមានសល់អ្វីជាដុំកំភួនឡើយ ព្រោះចាយវាយខ្ជះខ្ជាយពេក។ **សុខភាពៈ** ត្រូវយកចិត្តទុកដាក់ចំពោះរបបហូបចុកឱ្យបានទៀងទាត់ពេលវេលា។ **ស្នេហាៈ** ចំពោះគូស្នេហ៍មានភាពស្និទស្នាលដូចប្រក្រតី។ **គ្រោះថ្នាក់ៈ** ប្រយ័ត្នគ្រោះថ្នាក់ពេលដើរឆ្លងកាត់ផ្លូវថ្នល់។

រាសីឡើងខ្ពស់ត្រដែត។ **ការរកស៊ីៈ** បើមានបងប្អូនញាតិមិត្តស្កាត់មកបបួលរកស៊ីចូលហ៊ុនជាមួយចូរកុំខកខានឱ្យសោះ ព្រោះជាដៃគូរកស៊ីដែលមានចិត្តត្រង់ទៅត្រងមក់។ **ការងារៈ** ពេលប្រកបការងារអ្វីៗទទួលបានជោគជ័យហើយ ចូរកុំបញ្ចេញភាពអនួតក្រអឺតក្រទមឱ្យសោះ ទើបបានសុខកាយសប្បាយចិត្ត។ **សេដ្ឋកិច្ចៈ** មានចំណូលច្រើនពីគ្រប់ទិសទី អាចបង្កើនដើមទុនរកស៊ីនិងពង្រីកមុខរបរជួញដូរឱ្យកាន់តែធំ។ **សុខភាពៈ** អាចមានជំងឺមាត់ធ្មេញមករំខានខ្លះៗ។ **ស្នេហាៈ** ចំពោះកម្លោះក្រមុំអាចទាក់ទងសាងពន្លកស្នេហាបានដោយពុំមានឧបសគ្គអ្វីមករាំងស្កាត់ឡើយ។ **គ្រោះថ្នាក់ៈ** ពុំមានជួបគ្រោះថ្នាក់អ្វីធំដុំគួរឱ្យកត់សម្គាល់ឡើយ។

រាសីស្រុតចុះ។ **ការរកស៊ីៈ** ការរកស៊ីជួបគូប្រជែងជើងខ្លាំងចេញមកតតាំង។ ដូច្នេះត្រូវត្រៀមលក្ខណៈទុកសម្រាប់ទប់ទល់ជាមុន ទើបមិនបរាជ័យ។ **ការងារៈ** មុននិងរួបការងារជាមួយនិងអ្នកណា តោងចេះសង្កេតមើលសមាសភាពមនុស្សល្អនិងអក្រក់ឱ្យបានច្បាស់លាស់ ទើបមិនជាប់ពាក់ព័ន្ធក្នុងបទល្មើសផ្សេងៗ។ **សេដ្ឋកិច្ចៈ** ចំណូលខ្សត់ខ្សោយ ដូច្នេះត្រូវចេះចាយវាយដោយក្បិតក្បៀតបន្តិច ទើបមិនជួបវិបត្តិសេដ្ឋកិច្ចគ្រួសារ។ **សុខភាពៈ** ត្រូវឆ្លៀតពេលសម្រាក និងហាត់ប្រាណឱ្យបានច្រើន។ **ស្នេហាៈ** ចំពោះគូស្នេហ៍ប្រយ័ត្នមានជនទី៣ចូលជ្រៀតជ្រែក។ **គ្រោះថ្នាក់ៈ** ប្រយ័ត្នគ្រោះថ្នាក់ពេលឡើងចុះកាំជណ្តើរ។

រាសីល្អមធ្យម។ **ការរកស៊ីៈ** ការរកស៊ីមានការប្រកួតប្រជែងខ្លាំងណាស់ ដូច្នេះទាល់តែខិតខំប្រឹងប្រែងបន្តិច ទើបអាចបោះជំហានទៅមុខ។ **ការងារៈ** មិនត្រូវប្រគល់ការងារសំខាន់ៗឱ្យគេកាន់កាប់ធ្វើជំនួសឡើយ។ ប្រយ័ត្នគេកិបកែងយកផលប្រយោជន៍អស់។ **សេដ្ឋកិច្ចៈ** ពិតមែនតែមានចំណូលច្រើនគួរសមក្តី តែមិនត្រូវឱ្យគេខ្ចីលុយកាក់ ឬខ្ចីវត្ថុមានតម្លៃផ្សេងៗ។ ប្រយ័ត្នចាញ់បោកគេ។ **សុខភាពៈ** ត្រូវយកចិត្តទុកដាក់ចំពោះអនាម័យនៃការហូបចុក។ **ស្នេហាៈ** ចំពោះគូស្នេហ៍ប្រយ័ត្នមានអ្នកក្រៅនាំរឿងមកអុជអាល។ **គ្រោះថ្នាក់ៈ** ប្រយ័ត្នគ្រោះថ្នាក់លង់ទឹក។

រាសីស្រុតចុះ។ **ការរកស៊ីៈ** ការរកស៊ីមិនត្រូវចូលហ៊ុនជាមួយមនុស្សមានសម្តីផ្អែមនិងមានអំនួតអូតក្អេងក្អាងឡើយ។ ប្រយ័ត្នអាចចាញ់បោកគេរលាយទ្រព្យឆាប់។ **ការងារៈ** បើមានគេបបួលរួមការងារជាមួយ តោងប្រយ័ត្នប្រយែងក្រែងចាញ់បោកគេនាំអំពុលទុក្ខដាក់ខ្លួន។ **សេដ្ឋកិច្ចៈ** ចំណូលខ្សត់ខ្សោយនិងរកបានដោយកម្លាំងញើសឈាម។ ដូច្នេះកុំរកបានមកដោយតឹងតែចាយធូរឱ្យសោះ។ **សុខភាពៈ** ត្រូវឆ្លៀតពេលសម្រាកឱ្យបានច្រើន និងមិនត្រូវធ្វើការឱ្យហួសកម្លាំងឡើយ។ **ស្នេហាៈ** ចំពោះគូស្នេហ៍ទាល់តែឆាប់បញ្ចប់រឿងរកាំរកូស ទើបចំណងស្នេហ៍គងវង្ស។ **គ្រោះថ្នាក់ៈ** ប្រយ័ត្នគ្រោះថ្នាក់ចរាចរណ៍បើកបរពេលយប់ និងក្រោយពេលស្រវឹងជោគជាំ។

រាសីល្អមធ្យម។ **ការរកស៊ីៈ** ការរកស៊ីពិតមែនតែងើបឡើងបន្តិចក្តី។ តែអ្វីៗនៅតែជួបបញ្ហាច្រើន។ ដូច្នេះអាចបោះទុនរកស៊ីធុនល្មមកុំធំពេក។ **ការងារៈ** ទោះបានប្រកបការងារអ្វីក៏ដោយគឺមិនត្រូវធ្វើទាំងខ្ទះការពិចារណា ឬធ្វើទាំងតក់ក្រហល់ឡើយ ព្រោះកាលបើមានការថ្លោះធ្លោយអាចបង់ខាតផលប្រយោជន៍ច្រើន។ **សេដ្ឋកិច្ចៈ** ពិតមែនតែមានចំណូលច្រើនញគួរសមក្តី។ តែទុកមិនគង់ឡើយ ព្រោះមានបងប្អូនញាតិមិត្តស្កាត់មកររកស៊ីខ្ចីបេះបោចអស់ពីខ្លួន។ **សុខភាពៈ** ត្រូវចៀសវាងការល្មោភស៊ីល្មោភផឹក ទើបមិនអន្តរាយដល់ក្រពះពោះវៀន។ **ស្នេហាៈ** ចំពោះគូស្នេហ៍ទាល់តែចេះអត់ឱនឱ្យគ្នាទៅវិញទៅមក ទើបបានសុខ។ **គ្រោះថ្នាក់ៈ** ប្រយ័ត្នរលាកទឹកក្តៅ។

រាសីឡើងខ្ពត្រដែត។ **ការរកស៊ីៈ** ការរកស៊ីនៅតែបោះជំហានទៅមុខជាលំដាប់ ហើយបើទោះជាបានជួបគូប្រជែងជើងខ្លាំងយ៉ាងណាក្តី ក៏មិនភ័យញ្ញួយដែរ ព្រោះអាចយកប្រៀបឈ្នះជានិច្ច។ **ការងារៈ** ឱកាសការងារល្អៗបានមកដល់ហើយ ដូច្នេះត្រូវដុតដែដុតជើងបន្តិច ព្រោះពេលវេលាជាមាសប្រាក់ធ្វើច្រើនបានច្រើន។ **សេដ្ឋកិច្ចៈ** ពុំគ្រាន់តែមានចំណូលច្រើនប៉ុណ្ណោះទេ ព្រមទាំងមានគេយកលាភសក្តរៈមកឱ្យដល់ផ្ទះទៀតផង។ **សុខភាពៈ** នៅចុងខែមានជំងឺឈឺថ្កាត់ច្រើន។ **ស្នេហាៈ** ចំពោះគូស្នេហ៍មានភាពល្អូកល្អិនល្អណាស់។ **គ្រោះថ្នាក់ៈ** ពុំមានជួបគ្រោះថ្នាក់អ្វីធំដុំគួរឱ្យកត់សម្គាល់ឡើយ។

រាសីស្រុតចុះ។ **ការរកស៊ីៈ** មិនត្រូវហ៊ានប្រថុយប្រថានក្នុងការបណ្តាក់ទុនរកស៊ីដោយទ្រង់ទ្រាយធំឡើយ ហើយក៏មិនត្រូវប្រកបមុខរបរផ្នែកល្បែងស៊ីសងដែរ ទើបមិននាំអំពុល់ទុក្ខដាក់ខ្លួន។ **ការងារៈ** រាល់ការងារជួបរឿងរកាំរកូសច្រើន។ ដូច្នេះត្រូវចេះអត់ធ្មត់និងរម្ងាប់ចិត្តឱ្យបានត្រជាក់ ទើបរឿងតូចមិនអាចក្លាចជារឿងធំបាន។ **សេដ្ឋកិច្ចៈ** ពុំគ្រាន់តែមានចំណូលខ្សត់ខ្សោយប៉ុណ្ណោះទេ ព្រមទាំងត្រូវចាញ់បោគេបង់ខាតទ្រព្យទៀយផង។ **សុខភាពៈ** ត្រូវយកចិត្តទុកដាក់ក្នុងការហាត់ប្រាណនិងលេងកីឡាឱ្យបានច្រើន។ **ស្នេហាៈ** ចំពោះគូស្នេហ៍ជួបរឿងរកាំរកូសច្រើន។ **គ្រោះថ្នាក់ៈ** ប្រយ័ត្នគ្រោះថ្នាក់ចរាចរណ៍ក្នុងពេលបើកបរខ្ទះការប្រុងប្រយ័ត្ន។

រាសីឡើងខ្ពស់ត្រដែត។ **ការរកស៊ីៈ** អាចបណ្តាក់ទុនរកស៊ីដោយទ្រង់ទ្រាយតូចធំ ទោះផ្លូវទឹកផ្លូវគោកគឺសមប្រកបតែទាំងអស់ ព្រោះអាចប្រមូលផលចំណេញត្រឡប់ចូលផ្ទះយ៉ាងគាប់ចិត្ត។ **ការងារៈ** បើមានបងប្អូនញាតិមិត្តស្កាត់មកបបួលរួមការងារជាមួយចូរកុំខកខានឱ្យសោះ ព្រោះជាដៃគូការងារដែលមានចិត្តត្រង់ទៅត្រងមក។ **សេដ្ឋកិច្ចៈ** ពិតមែនតែមានចំណូលច្រើនក្តី តែចំពោះទ្រព្យក្តីក្រហាយកុំលូកដៃទទួលយកឱ្យសោះ។ **សុខភាពៈ** សុខភាពពុំមានបញ្ហាចោទឡើយ។ **ស្នេហាៈ** ចំពោះគូស្នេហ៍ប្រកបតែភាពផ្អែមត្រជាក់ដូចទឹកយ្មុំ។ **គ្រោះថ្នាក់ៈ** ពុំមានជួបគ្រោះថ្នាក់អ្វីធំដុំឡើយ។

រាសីល្អមធ្យម។ **ការរកស៊ីៈ** ការរកស៊ីជួញជិតល្អជាងជួញឆ្ងាយ ព្រោះដំណើរផ្លូវឆ្ងាយបើមិនបានជួបគ្រោះអាក្រក់ៗទេក៏បានត្រឹមតែបាតដៃទទេត្រឡប់ចូលផ្ទះវិញប៉ុណ្ណោះ។ **ការងារៈ** មិនត្រូវប្រគល់ការងារសំខាន់ៗឱ្យទៅមនុស្សដែលមិនទាន់ស្គាល់ច្បាស់លាស់កាន់កាប់ធ្វើជំនួសឡើយ។ ប្រយ័ត្នគេកិបកេងយកផលចំណេញអស់។ **សេដ្ឋកិច្ចៈ** ពិតមែនតែមានចំណូលច្រើនគួរសមក្តី តែពុំមានអ្វីជាដុំកំភួនឡើយឡើយ ព្រោះខ្ទង់ចំណាយធំជាងខ្ទង់ចំណូល។ **សុខភាពៈ** មិនត្រូវល្មោភផឹកឡើយ ទើបពុំអន្តរាយដល់ក្រពះពោះវៀននិងថ្លើម។ **ស្នេហាៈ** ចំពោះគូស្នេហ៍ប្រយ័ត្នមានអ្នកក្រៅនាំរឿងមកអុជអាល។ **គ្រោះថ្នាក់ៈ** ប្រយ័ត្នគ្រោះថ្នាក់មុខកាំបិតពូថៅ។



About JAPAN

ស្វែងយល់អំពីប្រទេសជប៉ុន

ទស្សនាវដ្តីញញឹមខ្មែរ សូមផ្តល់ជូននូវព័ត៌មានជាមូលដ្ឋានមួយចំនួនស្តីពីប្រទេសជប៉ុន ជូនប្រិយមិត្តអ្នកអានដើម្បីស្វែងយល់ពីប្រទេសជប៉ុន។ យើងខ្ញុំសង្ឃឹមថា ប្រិយមិត្តអ្នកអាននឹងមានឱកាសទៅទស្សនាប្រទេសជប៉ុន ក្នុងដំណើរកម្សាន្តផ្ទាល់ខ្លួន ជាមួយមិត្តភក្តិ ឬក្រុមគ្រួសារ នាថ្ងៃណាមួយ។

ព័ត៌មានមូលដ្ឋានរបស់ប្រទេសជប៉ុន

ចំនួនប្រជាជន

125.12 លាន នាក់

(ខែតុលា ឆ្នាំ 2021 / ការិយាល័យស្ថិតិនៃក្រសួងមហាផ្ទៃ និងស្ថិតិ)

ប្រទេសកម្ពុជាមានប្រមាណ 15.28 លាននាក់
(ខែមិនា ឆ្នាំ 2019 / ការិយាល័យស្ថិតិនៃក្រសួងផែនការ)

ផ្ទៃដី

378,000 km²

ប្រមាណពីរដងនៃទំហំផ្ទៃដីប្រទេសកម្ពុជា (កម្ពុជា: 181,035 km²)

ម៉ោងនៅជប៉ុន

ម៉ោងកម្ពុជា +2 ម៉ោង

ម៉ោង12ថ្ងៃត្រង់នៅប្រទេសកម្ពុជា គឺត្រូវនឹងម៉ោង2 រសៀលនៅប្រទេសជប៉ុន។

ភាសា

ភាសាជប៉ុន (ជាតាសាផ្លូវការ)

ប្រជាជនជប៉ុនភាគច្រើនមិនអាចនិយាយភាសាអង់គ្លេសបានដូច្នេះវាមានផលលំបាកបន្តិចចំពោះភ្ញៀវទេសចរ។ មានកន្លែងមួយចំនួនដែលសរសេរការណែនាំជាភាសាអង់គ្លេសដូចជា៖ នៅតាមស្ថានីយ៍រថភ្លើងជាដើម ជាទូទៅ មានផ្លាកសញ្ញាបង្ហាញផ្លូវ និងអគារជាដើមត្រូវបានសរសេរតែជាភាសាជប៉ុនប៉ុណ្ណោះ។ ប្រសិនបើអ្នកទៅទស្សនាប្រទេសជប៉ុន សូមត្រៀមទាញយកកម្មវិធីផែនទីណែនាំជាភាសាអង់គ្លេសជាជំនួយ។

រូបិយប័ណ្ណ

US$1 (ប្រហែល 4000រៀល)

= ប្រហែល 131 យ៉ែន

ដើមខែមករា ឆ្នាំ2023

* អត្រាប្តូរប្រាក់ប្រែប្រួលជារៀងរាល់ថ្ងៃ

នៅប្រទេសជប៉ុនមានក្រដាសប្រាក់៖ 1,000យ៉ែន 2,000យ៉ែន 5,000យ៉ែន 10,000យ៉ែន ហើយតម្លៃតូចជាងនេះគឺជាប្រាក់កាក់។ ដែលមាន 1យ៉ែន 5យ៉ែន 10យ៉ែន 50យ៉ែន 100យ៉ែន និង 500យ៉ែន។

● លុយធីប

នៅប្រទេសជប៉ុនមិនមានទំលាប់ឱ្យប្រាក់ធីបទេ។

ពន្ធ

ពន្ធលើការប្រើប្រាស់ 10%

ចាប់ពីឆ្នាំ2019 មក ជាគោលការណ៍ តម្លៃដែលបង្ហាញលើមុខទំនិញទាំងអស់ គឺជាតម្លៃដែលរួមបញ្ចូលពន្ធប្រើប្រាស់ ១0% ជាស្រេច។

● ហាងទំនិញដែលលើកលែងពន្ធ

នៅហាងទំនិញមួយចំនួនមានការលើកលែងពន្ធប្រើប្រាស់ 10%។ គិតត្រឹមខែមេសា ឆ្នាំ2019 សម្រាប់ជនបរទេស មានហាងចំនួនប្រហែល 50,000ហាង នៅទូទាំងប្រទេសជប៉ុន ជាពិសេសហាងលក់គ្រឿងអេឡិចត្រូនិច ហាងលក់ថ្នាំ ហាងលក់សម្ភារៈមួយចំនួន ត្រូវបានលើកលែងពន្ធប្រើប្រាស់។ ដូច្នេះដើម្បីទទួលការលើកលែងពន្ធប្រើប្រាស់នោះ ភ្ញៀវទេសចរត្រូវបង្ហាញលិខិតឆ្លងដែនដែន (ច្បាប់ដើម) ដែលមានត្រាសុំទិដ្ឋាការ។

▼ យោងពី

● **Website「JAPAN. Tax-Free Shop」**
https://tax-freeshop.jnto.go.jp/eng/index.php

អ្នកក៏អាចស្វែងរកព័ត៌មានបន្ថែមអំពីហាងទំនិញដែលលើកលែងពន្ធ និងរបៀបកាត់ពន្ធនៅតាមបណ្តាភ្នាក់ងារទេសចរតាមតំបន់នីមួយៗក្នុងប្រទេសជប៉ុនផងដែរ។

ការពិសាសុរា · ការជក់បារី

នៅក្នុងប្រទេសជប៉ុនការទទួលទានសុរា និងជក់បារីក្រោមអាយុ 20ឆ្នាំ ត្រូវបានហាមឃាត់។ ជនបរទេសស្នាក់នៅប្រទេសជប៉ុន ត្រូវគោរពតាមច្បាប់ជប៉ុន ដូច្នេះសូមប្រុងប្រយ័ត្ន! នៅភោជនីយដ្ឋាន និងហាងលក់បារីមួយចំនួន គឺទាមទារការបង្ហាញអត្តសញ្ញាណប័ណ្ណ ជាដើមដើម្បីផ្ទៀងផ្ទាត់អាយុ។

● កន្លែងជក់បារី

ការជក់បារីនៅតាមដងផ្លូវគឺត្រូវបានហាមឃាត់ដោយបទបញ្ញត្តិ នៃក្រុង ខណ្ឌ ឃុំ ភូមិជាច្រើនកន្លែង។ ប្រសិនបើអ្នកជក់បារី នៅក្រៅកន្លែងដែលកំណត់ គឺនឹងត្រូវពិន័យ ដូច្នេះចូរប្រុងប្រយ័ត្ន។ នៅតាមហាងកាហ្វេ និងភោជនីយដ្ឋានភាគច្រើន គឺមានបែងចែក ជាផ្នែកកន្លែងមិនជក់បារី និងផ្នែកកន្លែងជក់បារី។

តង់ស្យុងអគ្គិសនី

តង់ស្យុងអគ្គិសនីនៅប្រទេសជប៉ុនគឺ 100V ហើយប្រេកង់នៅ ភាគខាងកើតប្រទេសជប៉ុនគឺ 50Hz តែភាគខាងលិចប្រទេសជប៉ុន វិញគឺ 60Hz។ ដោយនៅប្រទេសកម្ពុជា គេប្រើប្រាស់គ្រឿងអគ្គិសនី តង់ស្យុង 200V ដូច្នេះអ្នកចំបាច់ត្រូវត្រៀមឧបករណ៍ប្តូរតង់ស្យុង អគ្គិសនីនៅក្នុងប្រទេសជប៉ុន។ យ៉ាងណាមិញ មានឧបករណ៍ អេឡិចត្រូនិចសេរីថ្មីមួយចំនួនដូចជា៖ កុំព្យូទ័រផ្ទាល់ខ្លួន និងទូរស័ព្ទ ថ្មីៗជាដើម អាចប្រើប្រាស់បានជាទូទៅទូទាំងពិភពលោកជាមួយ INPUT: 100-240V, 50-60Hz។ ម៉្យាងទៀត នៅក្នុងប្រទេសជប៉ុន រូបរាងនៃព្រីភ្លើងគឺជាប្រភេទមានរន្ធដោតពីររាងតំប៉ែតប្រភេទ A។ សូមប្រុងប្រយ័ត្នចំពោះឧបករណ៍ដែលមានឌុយដោតភ្លើងខុសគ្នា (ប្រភេទមូលប្រភេទមានជើងបីជាដើម) ពោលគឺអ្នកត្រូវការអាដាប់ទ័រ ដើម្បីដោតវា។

※ ប្រដាប់ផ្លាស់ប្តូរតង់ស្យុងអគ្គិសនី និងអាដាប់ទ័រដោតគឺអាចទិញបាននៅតាមហាង អគ្គិសនីធំៗក្នុងប្រទេសជប៉ុន។

ការទំនាក់ទំនង

● ការប្រើប្រាស់ទូរស័ព្ទដៃ

នៅក្នុងប្រទេសជប៉ុន ការប្រើប្រាស់ទូរស័ព្ទដៃគឺតម្រូវឱ្យមាន ការចុះកិច្ចសន្យាជាមួយក្រុមហ៊ុនទូរគមនាគមន៍ ហើយត្រូវបង់ថ្លៃ សេវាប្រចាំខែជារួម ទាំងការនិយាយទូរស័ព្ទ និងសេវាអ៊ីនធឺណិត។ បើប្រៀបធៀបនឹងប្រទេសកម្ពុជា ដែលគ្រាន់តែទិញស៊ីមកាត របស់ក្រុមហ៊ុនទូរគមនាគមន៍មកប្រើប្រាស់នោះ នៅប្រទេស ជប៉ុនវិញ គឺមានភាពស្មុគស្មាញបន្តិចចំពោះនីតិវិធីចុះឈ្មោះ ប្រើប្រាស់ ប៉ុន្តែនៅតាមព្រំលានយន្តហោះជប៉ុន មានលក់ស៊ីម កាតសម្រាប់ភ្ញៀវទេសចរណ៍បរទេស។

ការបំពេញពាក្យអនឡាញបញ្ជាក់ពីការចាក់វ៉ាក់សាំងកូវីដ១៩ សាលាកម្រិត្រអន្តោប្រវេសន៍ និងលិខិតរាយការណ៍គយ មុនចូលប្រទេសជប៉ុន

ដើម្បីសម្រួលនិតិវិធីត្រួតពិនិត្យការចាក់វ៉ាក់សាំងកូវីដ១៩ សាលាកប័ត្រអន្តោប្រវេសន៍ និងលិខិតរាយការណ៍គយ ភ្ញៀវ ទេសចរបរទេសគួរបំពេញពាក្យអនឡាញតាមរយៈគេហទំព័រ https://vjw-lp.digital.go.jp/en/ នេះជាមុន។ បន្ទាប់ពីបំពេញ បែបបទតាមអនឡាញខាងលើរួចរាល់ (ចំពោះការបញ្ជាក់ពី ការចាក់វ៉ាក់សាំងត្រូវការពេលមួយរយៈខ្លីដើម្បីទទួលចម្លើយ តបតាមអ៊ីម៉ែលចុះឈ្មោះ) ភ្ញៀវទេសចរគ្រាន់តែបង្ហាញ QR Code ទទួលបានក្រោយការបំពេញនៅលើទូរសព្ទដៃស្មាតហ្វូន លោកអ្នក ទៅកាន់ខោនធ័រត្រួតពិនិត្យ នោះជាការស្រេច។

ប្រព័ន្ធត្រួតពិនិត្យខាងលើនេះប្រើប្រាស់បាននៅតាមអាកាសយានដ្ឋានខាងក្រោម៖

- Narita International Airport
- Haneda Airport
- Kansai International Airport
- Chubu Centrair International Airport
- Fukuoka Airport
- New Chitose Airport

ថ្ងៃឈប់សម្រាក

ថ្ងៃឈប់សម្រាកប្រចាំឆ្នាំ2023 មានដូចខាងក្រោម។ នៅថ្ងៃឈប់សម្រាកត្រួតគ្នាចំថ្ងៃអាទិត្យគឺត្រូវផ្លេរទៅឈប់ នៅថ្ងៃចន្ទជំនួសវិញ។ នៅប្រទេសជប៉ុនគេធ្វើដំណើរកម្សាន្តនៅថ្ងៃចុងសប្តាហ៍ នៅមុនថ្ងៃបុណ្យមួយថ្ងៃ ឬថ្ងៃបុណ្យ វិស្សមកាល បុណ្យ OBON "បុណ្យភ្ជុំបិណ្ឌជប៉ុន" (ថ្ងៃទី13 ដល់ទី15 ខែសីហា)បុណ្យចូលឆ្នាំថ្មី (ថ្ងៃទី29 ខែធ្នូ ឆ្នាំ2023~ថ្ងៃទី3 ខែមករា ឆ្នាំ2024) ដែលធ្វើឱ្យចរាចរណ៍មានភាពមមាញឹក និងតម្លៃសណ្ឋាគារឡើងថ្លៃជាដើម។

ខែមករា	ថ្ងៃទី 01	ថ្ងៃបុណ្យចូលឆ្នាំសែកល		ថ្ងៃទី 05	ថ្ងៃបុណ្យកុមារ
	ថ្ងៃទី 09	ថ្ងៃបុណ្យពេញវ័យ	ខែកក្កដា	ថ្ងៃទី 17	ថ្ងៃបុណ្យសមុទ្រ
ខែកុម្ភៈ	ថ្ងៃទី 11	ទិវាថ្ងៃស្ថាបនាជាតិ	ខែសីហា	ថ្ងៃទី 11	ថ្ងៃបុណ្យភ្នំ
	ថ្ងៃទី 23	ពិធីបុណ្យចម្រើនព្រះជន្មព្រះចៅអធិរាជ្យ	ខែកញ្ញា	ថ្ងៃទី 18	ថ្ងៃរំលឹកគុណមនុស្សចាស់
ខែមិនា	ថ្ងៃទី 21	ថ្ងៃនិទាឃរដូវ		ថ្ងៃទី 23	ទិវាសមរាត្រី
ខែមេសា	ថ្ងៃទី 29	ថ្ងៃបុណ្យ Showa	ខែតុលា	ថ្ងៃទី 09	ថ្ងៃបុណ្យកីឡាជាតិ
ខែឧសភា	ថ្ងៃទី 03	ទិវារំលឹករដ្ឋធម្មនុញ្ញ	ខែវិច្ឆិកា	ថ្ងៃទី 03	ទិវាវប្បធម៌
	ថ្ងៃទី 04	ទិវានៃថ្ងៃបៃតង		ថ្ងៃទី 23	ទិវាពលកម្ម

អាកាសធាតុនិងរដូវ

អាកាសធាតុ

តំបន់ភាគច្រើននៃប្រទេសជប៉ុន គឺស្ថិតនៅតំបន់ក្តៅល្មមដែលមានសីតុណ្ហភាពខុសៗគ្នាចែកចេញជាបួនរដូវ។ ម្យ៉ាងទៀត សណ្ឋានដីប្រទេសជប៉ុនមានរាងទ្រវែងដែលលាតសន្ធឹងពីភាគខាងត្បូងទៅខាងជើង ហើយទទួលឥទ្ធិពលពីខ្យល់រដូវ និងចរន្តទឹកសមុទ្រដែលនាំអោយអាកាសធាតុតាមតំបន់នីមួយៗមានភាពខុសៗគ្នា។ កោះ Hokkaido ដែលស្ថិតនៅភាគខាងជើងបង្អស់នៃប្រទេសជប៉ុន គឺមានភាពត្រជាក់ខ្លាំងក្នុងរដូវរងា តែកោះ Okinawa ដែលស្ថិតនៅភាគខាងត្បូងបង្អស់នៃប្រទេសជប៉ុនវិញ មានសីតុណ្ហភាពក្តៅល្មមពេញមួយឆ្នាំ ទោះបីជារដូវរងាក៏មិនរងាខ្លាំងដែរ។

លើសពីនេះទៀត ដោយសារតែជប៉ុនមានជួរភ្នំខ្ពស់ៗច្រើន ធ្វើឱ្យរដូវរងាមានពពក ឬព្រិល និងភ្លៀងជាញឹកញាប់នៅក្នុងប៉ែកសមុទ្រជប៉ុន ប៉ុន្តែប៉ែកមហាសមុទ្រប៉ាស៊ីហ្វិកវិញ គឺភាគច្រើនមានមេឃស្រលះ។

រដូវភ្លៀង

ជាទូទៅ ចាប់ពីចុងខែមិថុនា ដល់ចុងខែកក្កដា មានភ្លៀងធ្លាក់ច្រើនលើកលែងតែនៅកោះ Hokkaido។ ភ្លៀងនៅប្រទេសជប៉ុន មិនមែនជាភ្លៀងធ្លាក់ខ្លាំងៗនោះទេ តែវាភាគច្រើនជាភ្លៀងរលឹមស្រិចៗរយៈពេលយូរ។

ខ្យល់ព្យុះ

ព្យុះស៊ីក្លូនត្រូពិចកើតនៅលើសមុទ្រភាគខាងត្បូង បក់ឆ្លងកាត់ប្រទេសជប៉ុនជាច្រើនដងពីខែកក្កដា ដល់ខែតុលា។ វានាំមកជាមួយខ្យល់បក់និងភ្លៀងខ្លាំង ពេលបក់ឆ្ពោះទៅភាគខាងជើងម្តងៗ ដូច្នេះបណ្តាលឱ្យមានគ្រោះមហន្តរាយដូចជា៖ ការធ្លាក់បាក់ដីភ្នំ នីរ៉ូទឹកសមុទ្រឡើងខ្ពស់ និងទឹកជំនន់ជាដើម។

រដូវ

រដូវនៅប្រទេសជប៉ុនចែកជា៤គឺ៖ រដូវផ្កាឫក រដូវក្តៅ រដូវស្លឹកឈើជ្រុះ និងរដូវរងា។ នៅតាមរដូវនីមួយៗ គេអាចសប្បាយរីករាយជាមួយទេសភាពខុសៗគ្នាក្នុងរដូវទាំង៤ នោះ ព្រមទាំងពិធីបុណ្យនានា និងចំណីអាហារផ្សេងៗជាដើម។

រដូវផ្កាឫក

បន្ទាប់ពីរដូវរងាកន្លងផុត រដូវផ្កាឫកនឹងឈានមកដល់។ មានផ្កា SAKURA និងផ្កាផ្សេងៗទៀតជាច្រើនរីកស្គុសស្គាយ ដែលវាក៏ជារដូវធ្វើឱ្យមានអារម្មណ៍ស្រស់ស្រាយផងដែរ។ យ៉ាងណាមិញ ផ្កា SAKURA រីកចាប់ពីចុងខែមីនា ទៅដើមខែមេសា ក៏ប៉ុន្តែក្នុងអំឡុងពេលនេះ សម្រាប់អ្នកទេសចរមកពីប្រទេសកម្ពុជាវិញ ច្បាស់ជាមានអារម្មណ៍ត្រជាក់នៅឡើយ ដូច្នេះ បើអ្នកទៅទស្សនាក្នុងរដូវនេះ គួរត្រៀមការពារសម្លៀកបំពាក់ការពាររងា។

● កន្លែងទស្សនា · ព្រឹត្តិការណ៍

ការមើលផ្កា SAKURA និងផ្កាដទៃទៀត

បើនិយាយពីរដូវផ្កាឫក គេសំដៅលើផ្កា SAKURA។ មានភ្ញៀវទេសចរបរទេសជាច្រើនមកទស្សនាផ្កា SAKURA នៅប្រទេសជប៉ុន។ គួររំលឹកថា ផ្កា SAKURA រីកអាស្រ័យលើអាកាសធាតុនៃឆ្នាំនិងតាមតំបន់នីមួយៗ ដូច្នេះអ្នកគួរស្វែងរកព័ត៌មានបន្ថែមលើបណ្តាញអ៊ីនធឺណិតជាដើម។ ផ្កា SAKURA រីកចាប់ពីភាគខាងត្បូងនៃប្រទេស ហើយជារៀងរាល់ឆ្នាំនៅចុងខែមីនាទៅដើមខែមេសា ផ្កា SAKURA នៅតូក្យូរីកស្រស់ស្អាតគួរឱ្យគយគន់។

រដូវក្តៅ

វាជារដូវដែលព្រះអាទិត្យបញ្ចេញពន្លឺ និងក្តៅខ្លាំង។ នៅពេលរដូវភ្លៀងដែលចាប់ពីចុងខែមិថុនា ដល់ពាក់កណ្តាលខែកក្កដាកន្លងផុតទៅភ្លាមនោះ សីតុណ្ហភាពនឹងកើនយ៉ាងលឿនដែលបញ្ជាក់ថារដូវក្តៅមកដល់ហើយ។ សីតុណ្ហភាពខ្ពស់បំផុតកើនជិតដល់៤០អង្សាសេ ហើយដោយរដូវក្តៅនៅប្រទេសជប៉ុនមានសំណើមខ្ពស់ ដូច្នេះថ្ងៃខ្លះអាចមានអារម្មណ៍ថាក្តៅជាងប្រទេសកម្ពុជាទៅទៀត។

● កន្លែងទស្សនា · ព្រឹត្តិការណ៍

បុណ្យរដូវក្តៅ កម្មវិធីបាញ់កាំជ្រួច ឡើងភ្នំ FUJI ហែលទឹកសមុទ្រ ជាដើម

នៅប្រទេសជប៉ុន មានវិស្សមកាលរដូវក្តៅ ហើយមានព្រឹត្តិការណ៍ជាច្រើនប្រារព្ធឡើង ជាពិសេស កម្មវិធីបាញ់កាំជ្រួចគឺជាពិធីប្រពៃណីនៅរដូវក្តៅ។ វាត្រូវបានគេប្រារព្ធធ្វើឡើងតាមតំបន់នីមួយៗ ទូទាំងប្រទេស ហើយកាំជ្រួចរាប់ពាន់ទៅរាប់ម៉ឺនគ្រាប់នឹងត្រូវបាញ់បង្ហោះទៅលើមេឃ។

● សីតុណ្ហភាព និងបរិមាណភ្លៀងប្រចាំឆ្នាំ (ជប៉ុន / កម្ពុជា)

សីតុណ្ហតាមជាមធ្យម Tokyo ភ្នំពេញ

កំពស់ទឹក Tokyo ភ្នំពេញ

ទិន្នន័យនៃតារាងមធ្យមភាគខាងក្រោម គិតពីខែសីហា ឆ្នាំ2015 រហូតដល់ខែកក្កដា ឆ្នាំ2019។ ទិន្នន័យនេះដកស្រង់ពីការបង្ហាញពីឧតុនិយមនៃទីភ្នាក់ងារឧតុនិយមជប៉ុន។



រដូវស្លឹកឈើជ្រុះ

ជារដូវដែលមានកំដៅនិងសំណើមធ្លាក់ចុះ ហើយជារដូវដែលងាយស្រួលរស់នៅ។ ក្រៅពីស្លឹកឈើជ្រុះដែលមានប្រជាប្រិយភាពសម្រាប់ជនបរទេស រដូវស្លឹកឈើជ្រុះក៏ជារដូវដែលមានចំណីអាហារឆ្ងាញ់ៗផងដែរ។ បើអញ្ជើញមកលេងក្នុងរដូវនេះ សូមកុំភ្លេចសាកល្បងម្ហូបអាហារជប៉ុនក្នុងរដូវកាលនេះ។

● កន្លែងទស្សនា · ព្រឹត្តិការណ៍

ទស្សនាស្លឹកឈើប្រែពណ៌ក្រហម ផ្កា Cosmos នឹងការកំសាន្តនៃរដូវស្លឹកឈើជ្រុះជាដើម

ពណ៌ស្លឹកឈើតាមដើមឈើលើភ្នំនិងដើមឈើតាមផ្លូវដែលប្រែពីពណ៌បៃតងទៅជាពណ៌ក្រហមឬពណ៌លឿងជាដើម គឺពិតជាស្រស់ស្អាត ដែលយើងអាចនិយាយបានថាជាសម្រស់សិល្បៈនៃធម្មជាតិ! ដោយហេតុនេះហើយ ទើបរដូវស្លឹកឈើជ្រុះក៏ដូចរដូវផ្កា SAKURA រីក នៅ Kyoto Nara និង Nikko ជាដើមគឺជាចំណុចដែលមានភ្ញៀវទេសចរជាច្រើនមកទស្សនា។

រដូវរងា

វាជារដូវត្រជាក់បំផុតប្រចាំឆ្នាំ។ បើអ្នកទៅកម្សាន្តប្រទេសជប៉ុនក្នុងរដូវនេះ សូមរៀបចំសម្លៀកបំពាក់ការពារត្រជាក់សម្រាប់រដូវរងានេះ។ បើទោះបីជាវាត្រជាក់ខ្លាំងបន្តិច ប៉ុន្តែទេសភាពព្រិលដែលពុំមាននៅក្នុងប្រទេសកម្ពុជា គឺពិតជាគួរឱ្យទាក់ទាញសម្រាប់ជនជាតិខ្មែរមកទស្សនា។

● កន្លែងទស្សនា · ព្រឹត្តិការណ៍

ព្រិល ស្គី (កីឡារដូវត្រជាក់) ពិធីបុណ្យចូលឆ្នាំថ្មី ជាដើម

យ៉ាងណាមិញ វាមិនមានព្រិលធ្លាក់គរនៅគ្រប់កន្លែងទូទាំងប្រទេសក្នុងរដូវរងានោះទេ។ កន្លែងពេញនិយមសម្រាប់ភ្ញៀវទេសចរដែលចង់ប៉ះព្រិលគឺមានៈ រមណីយដ្ឋានជិះស្គីដ៏ពេញនិយមស្ថិតនៅកោះ Hokkaido និងខេត្ត Nagano ហើយអ្នកក៏អាចរីករាយជាមួយនឹង ONSEN (ទឹកក្តៅធម្មជាតិ) នៅ Zao នៃខេត្ត Yamagata និងទេសភាពព្រិលនៅ Shirakawago នៃខេត្ត Gifu ដែលជាកន្លែងមានផ្ទះបែបប្រពៃណីបុរាណ ដែលត្រូវបានចុះក្នុងបញ្ជីបេតិកភណ្ឌពិភពលោកទាំងនេះផងដែរ។

Map of Japan

ផែនទីជប៉ុន

ក្រុមហ៊ុនជំនាញអំពីកម្ពុជា
Cambodia Joho Service inc.

- សេវាបកប្រែអត្ថបទឬផ្ទាល់មាត់ ជាភាសាជប៉ុន-ខ្មែរ
- ស្រាវជ្រាវព័ត៌មានផ្នែកពាណិជ្ជកម្មទៅតាមតម្រូវការរបស់អតិថិជន
- រៀបចំសកម្មភាពពាណិជ្ជកម្មជាកញ្ចប់
- បោះពុម្ពផ្សាយទស្សនាវដ្តី "ញញឹម" និង "ញញឹមខ្មែរ"
- ផ្សព្វផ្សាយដំណឹងជ្រើសរើសបុគ្គលិកនិងពាណិជ្ជកម្មផ្សេងៗតាមវិបសាយ
- ឌីហ្សាញនាមប័ណ្ណ ខិតប័ណ្ណ កាតាឡុក ប៊ូស្ទឺ ប៉ាណូពាណិជ្ជកម្មជាដើម
- លក់ផលិតផលសិប្បកម្មក្នុងស្រុក ជាពិសេសកុលាលភាជន៍ខេត្តកំពង់ឆ្នាំង

អាស័យដ្ឋាន : ផ្ទះលេខ ៧៦Eo ផ្លូវលេខ ៤៥៤ សង្កាត់ ទួលទំពូង ខណ្ឌ ចំការមន ភ្នំពេញ, កម្ពុជា
ទូរស័ព្ទ : ០១២ ៥០០ ០៥២ / ០១៦ ៦៥៧ ២៩០, cjs@cisinc.co.jp

ការសាកល្បងថ្មីរបស់ហាងនំឃុគឃី

ទឹកប៉េងប៉ោះ និងទឹកជ្រលក់ Worcestershire Sause ផលិតឡើងដោយដៃសុទ្ធសាធ

អបអរសាទរខួបទី ១៥ឆ្នាំ
15th Anniversary Angkor Cookies

ហាងយើងខ្ញុំមាន "ទឹកប៉េងប៉ោះ" ដែលផលិតឡើងពីផ្លែប៉េងប៉ោះទុំស្រស់ល្អទាំងសំបក និង "ទឹកជ្រលក់ Worcestershire Sause" ដែលប្រើទឹកស្ករកាវ៉ាមេលពិសេស។ នំ "ឃុកឃី" នេះផលិតឡើងដោយស្នាដៃបុគ្គលិកប្រចាំហាងម្តងមួយបន្ទះៗ ដោយពុំប្រើប្រាស់សារធាតុគីមីរក្សាគុណភាព។ ទឹកប៉េងប៉ោះនេះមានគុណភាពពិសេស អាចប្រើប្រាស់ជាទឹកជ្រលក់ និងគ្រឿងផ្សំសម្រាប់ម្ហូបមួយចំនួនដូចជា៖ Omelette rice មីអ៊ីតាលី (Naporitan) ជាដើម។ ចំណែកទឹកជ្រលក់ Worcestershire Sause រសជាតិហឺរអាចប្រើសម្រាប់ម្ហូប Croquette និង Pork Cutlet ។ លោកអ្នកអាចរីករាយជាមួយមុខម្ហូបដទៃទៀតបាន ដោយប្រើប្រាស់រសជាតិទឹកជ្រលក់ទាំងពីរផ្សំចូលគ្នា។ សូមអញ្ជើញសាកល្បង។

CHOCOLATE with Angkor Cookies

Milk Chocolate / Dark Chocolate
ផលិតដោយយកចិត្តទុកដាក់ម្តងមួយបន្ទះៗជ្រលក់ជាមួយសូកូឡាដែលមានរសជាតិកាកាវ៧០%។

ANGKORCOOKIES
INFO@ANGKORCOOKIES.COM

Cafe Khmer Time

Open: 9:30am - 7pm
Tel: 017-976-660
every day!

"Khmer Time" គឺជាហាងកាហ្វេតែមួយជាមួយនឹងហាងនំ "Angkor Cookies" នៅខេត្តសៀមរាប

Add: តាមផ្លូវទៅអង្គរវត្ត (ទល់មុខ សណ្ឋាគារ Sofitel Angkor Phokeethra Golf & Spa Resort) ខេត្តសៀមរាប

© CJSinc. 2023

NEW

Renewal in March 2018

ញញឹមខ្មែរ

NyoNyum Khmer

Japan, your neighbor

SINCE 2014

ទស្សនាវដ្ដី “ញញឹមខ្មែរ” ផ្សព្វផ្សាយអំពីវប្បធម៌ និងសង្គមជប៉ុន នៅកម្ពុជា។

ក្នុងគោលបំណងចូលរួមពង្រឹងចំណងមិត្តភាព កម្ពុជា និង ជប៉ុន ឱ្យកាន់តែស្អិតស្អាលថែមទៀត ក្រុមការងារយើងខ្ញុំ ខិតខំណែនាំនូវប្រធានបទព័ត៌មានចុះផ្សាយថ្មី។ ទាក់ទងនឹងប្រទេសជប៉ុន ដែលមានខ្លឹមសារ និងអត្ថប្រយោជន៍សម្រាប់ប្រិយមិត្តអ្នកអាន ដើម្បីធ្វើការស្វែងយល់អំពីប្រទេសជប៉ុន។

ទាំងខ្លឹមសារ និងការរចនា ត្រូវបានធ្វើឡើងឱ្យកាន់តែងាយស្រួលក្នុងការអាន និងទាន់សម័យ។

សូមប្រិយមិត្តអ្នកអាន រីករាយជាមួយនឹងការចុះផ្សាយរបស់យើងខ្ញុំ។